ញ៉ុក . ថែម

# មហាវេស្សន្តរជាតក



## ភាគទី ៣

ផ្សាយចេញពី "មជ្ឈមណ្ឌលវប្បធម៌ខ្មែរ"
រក្សាសិទ្ធិគ្រប់យ៉ាង
ព.ស ២៥៤៦ គ.ស ២០០២

# មហាវេស្សន្តរជាតក

## សម្រាប់ទេសន៍

## ទី ៣

## ធានកណ្ឌ

ប្រដាប់ដោយគាថា ២០៩
បោះពុម្ពលើកទី ១
ចំនួន ១.០០០ ច្បាប់


ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនាបណ្ឌិត្យ
ព.ស ២៥០៩



Websites: WatKhemaraRatanaram.org or WatKhmers.org

# មហាវេស្សន្តរជាតក

## ទី៣

## ទានកណ្ឌ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ផុស្សតីបិ ខោ ទេវី បុត្តស្ស មេ កាផុកសាសនំ អាគតំ ភិន្ទុ ខោ កាហេតិ អហំ តត្ថា ជានិស្សាមីតិ ។

ភោ សាធវោ ហៃសាធុសប្បុរសផងទាំងឡាយអើយ រីព្រះនាងសុបារសុប្បតីទេវី ដ៏ជាស្រីមានលក្ខិណាប្រសើរ បានឮពត៌មានពុំក្បែរមក្សាន្ត អំពីព្រះវេស្សន្តរ ដ៏ជាស្តេចព្រះរាជបុត្រនោះហើយក្ងរ ព្រះនាងទ្រង់ព្រះចិន្តាដូច្នេះថា ឱ!ដូចអញគិតនេះហើយធ្វើម្តេចអញនឹងបានដឹង ទុក្ខកូនអញនោះឲ្យច្បាស់ ព្រះនាងទ្រង់ព្រះចិន្តាដូច្នេះហើយ ក៏មានព្រះបន្ទូលហៅនាយរាជរថឲ្យទឹម នូវសេះអាជានេយ្យដ៏ប្រសើរមក ហើយឲ្យយកកម្រាលដ៏ពិចិត្រទៅក្រាលហើយឲ្យបាំងនីទៅនូវស្វេតច្ឆ័ត្រដ៏ប្រសើរ ទើបព្រះនាងឡើងគង់លើព្រះរាជរថនោះ ហើយបរទៅដាក់នៅមុខព្រះលានទៀបទ្វារព្រះរាជ

Websites: WatKhemaraRatanaram.org or WatKhmers.org

មន្ទីរនៃព្រះបាទស្រីវេស្សន្តរ ដ៏ជាព្រះរាជបុត្រ ដ៏មានសិរីសួស្តីប្រសើរនោះ ។ ព្រះនាងព្ទស័ព្ទឃោបំ នៃព្រះវេស្សន្តរ នូវព្រះនាងមទ្រីទ្រង់ព្រះកន្សែងព្ទសូររងំ ផ្សំនូវស្រីស្នំក្រមការបំរើផងនោះ មុខគួរឱ្យអាសូរករុណា ក្រៃពេកហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ វីអាចិធមិឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថៃងច្បាស់ លុះព្រះបានត្រាស់សព្វេជ្ញតាញាណហើយ ទ្រង់មានព្រះបន្ទូលសូត្រជាបាទគាថាដូច្នេះថា ៖

តេសំ លាលបិតំ សុត្វា បុត្តស្ស សុណិសាយ ច
កលូនំ បរិទេវេសិ រាជបុត្តី យសស្សិនី ។
សេយ្យោ វិសំ មេ ខាយិតំ បបាតា បបតេយ្យហំ
រជ្ជុយា ពជ្ឈមិយាហំ
កស្មា វេស្សន្តរំ បុត្តំ បព្វាជេន្តិ អទូសកំ ។
អជ្ឈាយកំ ទានបតឹ យាចយោគំ អមច្ឆរឹ

Websites: WatKhemaraRatanaram.org or WatKhmers.org

កស្មា វេស្សន្តរំ បុត្តំ   បព្វាជេន្តិ អទូសកំ ។
បូជិតំ បដិរាជូហិ   កិត្តិមន្តំ យសស្សិនំ
កស្មា វេស្សន្តរំ បុត្តំ   បព្វាជេន្តិ អទូសកំ ។
មាតាបេតិភរំ ជន្តុំ   កុលេ ជេដ្ឋាបចាយិនំ
កស្មា វេស្សន្តរំ បុត្តំ   បព្វាជេន្តិ អទូសកំ ។
រញ្ញោ ហិតំ ទេវហិតំ   ញាតីនំ សខិនំ ហិតំ
ហិតំ សព្វស្ស រដ្ឋស្ស
កស្មា វេស្សន្តរំ បុត្តំ   បព្វាជេន្តិ អទូសកន្តិ ។

ហៃភិក្ខុផងទាំងឡាយអើយ  រីព្រះនាងសុបារសុប្បតីទេវី ដ៏ជារាជបុត្រីស្តេចមទ្ទរាស្ត្រ ដ៏មានយសបរិវារច្រើននោះ ព្រះនាងឮស័ព្ទទំនួញយោបំនៃព្រះវេស្សន្តរ  ដ៏ជាសម្តេចរាជបុត្រក្តី  សម្តេចព្រះរាជមទ្រីដ៏ជាបុត្រីប្រសាក្តី  សឹងទូញយំជាទុក្ខមុខគួរឲ្យអាសូរ  ករុណាក្រៃពេក ។  ហៃសាធុសប្បុរសផងទាំងឡាយអើយ  រីព្រះនាងសុបារសុប្បតីក្សត្រិយ៍ឧត្តម  ទ្រង់ព្រះកន្សែងស្រដីដូច្នេះថា  ឱនរណាអើយ

ដែលដឹងថ្នាំពិសនោះ ក៏យកមកឲ្យអញ ! អញនឹងផឹឲ្យស្លាប់ទៅ! ទើបជាការគាប់ប្រសើរក្រៃលែង បើអញនឹងរស់នៅវិញនោះ ឃើញថាពុំប្រសើរឡើយ ។ ពុំនោះសោត អញនឹងឡើងទៅលើដំបូលប្រាសាទនោះហើយ ក៏អញនឹងយកស្បៃមួយចងឲ្យខ្ជាប់ ហើយអញបម្រះឲ្យធ្លាក់ចុះ ដើម្បីឲ្យស្លាប់ទៅទើបប្រសើរក្រៃលែង ជាងរស់នៅជាមនុស្សនេះមិញ ។ ឱហេតុអ្វីអើយ ក៏អ្នកស្រីពិរាស្រ្តផងទាំងឡាយ គេបំបរបង់បាវេស្សន្តរ កូនអញជាអ្នកឥតទោសនេះ ឲ្យប្រាសលែងនៅស្រុក ? ឱ! ដូចអញគិតនេះហើយ ព្រះវេស្សន្តរកូនអញនេះជាអ្នកឥតទោស ប៉ុន្តែជាអ្នកមានអធ្យាស្រ័យអាល័យ ចង់តែឲ្យទានពុំចេះមានកំណាញ់ទ្រព្យអ្វីឡើយ ។ ឱ!បាវេស្សន្តរកូនអញនេះ ជាអ្នកមានយសបរិវារព្រល្បីប្រាកដសព្វប្រទេសនានា សឹងនាំដង្វាយមកថ្វាយជាច្រើន ។ ឱ! បាវេស្សន្តរអើយ បាជាអ្នកឥតទោស ហេតុអ្វីក៏អ្នកស្រីពិរាស្រ្តផងទាំងឡាយ មកបំបរបង់ចេញពីស្រុកនេះ មួយនីសោត បាវេស្សន្តរជាអ្នកឥតទោស ការនៅសព្វថ្ងៃនេះ តែងនឹងបំរើម្តាយឪពុក ទំនុកបំរុងចាស់ព្រឹទ្ធាចារ្យ មួយសោត បាវេស្សន្តរជាអ្នកឥតទោសនៅសព្វថ្ងៃនេះ ជា

Websites: WatKhemaraRatanaram.org or WatKhmers.org

អ្នកអាល័យចង់ធ្វើប្រយោជន៍ នៃទេវតានិងមហាក្សត្រ ទំនុកបំរុងញាតិមិត្តផងទាំងឡាយ ជាអ្នកធ្វើប្រយោជន៍ដល់ផែនដីទាំងមូល ចុះហេតុអ្វី ក៏អ្នកស្រីពិរាស្រ្ត មកបំបរបង់បាវេស្សន្តរ ចេញពីស្រុកនេះ ?

ឥតិ សា កាលូនំ បរិទេវិត្វា បុត្តញ្ច សុណិសញ្ច អស្សាសេត្វា រញ្ញោ សន្តិកំ គន្ត្វា អាហ ។ ហែសប្បុរសទាំងឡាយអើយ រីព្រះនាងសុបារសុប្បតី ដ៏ជាស្រីប្រកបនូវលក្ខិណាដ៏ប្រសើរ ព្រះនាងទ្រង់ព្រះកន្សែងរួចហើយ ទ្រង់ក៏លួងលោមព្រះវេស្សន្តរ នូវព្រះនាងមទ្រី ដ៏ជាព្រះរាជបុត្រីប្រសានោះថា ហែអ្នកទាំង ២ អម្ចាស់ម្ចាស់ម្តាយអើយ ម្តាយនឹងទៅកាន់ព្រះបាទស្រីសញ្ជ័យ ដ៏ជាព្រះវរបិតាអ្នកទាំង ២ ហើយម្តាយនឹងស្រដីលោមព្រះបាទស្រីសញ្ជ័យ កុំឲ្យព្រះអង្គយកពាក្យអ្នកស្រីពិរាស្រ្តជាការនោះឡើយ ។ ហែសប្បុសផងទាំងឡាយអើយ រីព្រះនាងសុបារសុប្បតី លួងលោមព្រះរាជបុត្រាបុត្រីទាំង ២ នោះហើយ ពុំយូរឡើយព្រះនាងទៅទូលព្រះបាទស្រីសញ្ជ័យដោយបាទព្រះគាថាដូច្នេះ ៖

មជ្ជីវ បលិតានិ អម្ហាវ បតិតា ធមា

Websites: WatKhemaraRatanaram.org or WatKhmers.org

ឯវំ ហេស្សតិ តេ វដ្ឋំ    បញ្ញាជេន្តិ អចូសកំ ។
ហំសោ និក្ខិណាបត្តោវ    បល្វលស្មឹ  អនូទកោ
អបរិណ្ណោ អមច្ចេហិ    ឯកោ រាជា វិហិយ្យសិ ។
តន្តំ ព្រូមិ មហារាជ    អត្ថោ តេ មា ឧបច្ចគា
មា នំ សិវិនំ វចនា    បញ្ញាជេសិ អចូសកន្តិ ។

បពិត្រព្រះបាទស្រីសញ្ជ័យ ដ៏ជាមហាក្សត្រប្រសើរអើយ ចូរអម្ចាស់ស្តាប់ពាក្យអញខ្ញុំដូច្នេះអម្ចាស់អើយ បើឥតនឹងបាវេស្សន្តរ ដ៏ជាព្រះរាជបុត្រនោះហើយ  រីរាជ្យសម្បត្តិអម្ចាស់នេះ នឹងអន្តរធានហោង ។ ហើយអស់មនុស្សផងទាំងឡាយ ពិតជាមើលងាយដូចឃ្មុំឥតមេ ទំនើងសត្វផងទាំងឡាយនឹងមកឆីងាយក្តាត់ហោង ។ មួយសោត បីដូចផ្លែស្វាយទុំ ហើយជ្រុះមកលើក្រឡាមហាប្រឹថពីនោះ នឹងជាចំណីនៃសត្វទាំងឡាយ វាឆីរាត់រាយខ្ចាត់ខ្ចាយទៅ ។ បពិត្រអម្ចាស់អើយ រីបាវេស្សន្តរដ៏ជាព្រះរាជបុត្រនេះ ជាអ្នកឥតទោសកំហុស ដ៏មានសំដីនោះពីរោះផ្អែមល្ហែមណាស់ក្ទូវ មិនគួរបំបរបង់គាត់តាមដោយនូវពាក្យអ្នកស្រីពិរាស្រ្តនោះឡើយ ។ មួយសោត

អម្ចាស់អើយ នាសព្វថ្ងៃនេះបើដូចរាជហង្ស ដ៏មីរដេរដាសដោយបរិវារផងទាំងឡាយនោះ ២ ម៉ឺន កាលណារាជហង្សនោះបាក់ចំអេងរលើងស្លាប ដួលស្រប៉ាបទៅលើភក់នោះ តើលំបាកម្ដេចមិញ? អម្ចាស់អើយ! ថាបើព្រះអង្គឥតអំពីបាវេស្សន្តរ ដ៏ជាព្រះរាជបុត្រនោះហើយ អម្ចាស់ប្រាកដគង់នៅតែ ១ អង្គឯង នោះសមនឹងស្វាត់ ឥតអាមាត្យមកគាល់បំរើដល់មួយឡើយ ។ បពិត្រមហារាជអើយ វីបាវេស្សន្តរជាអ្នកឥតទោស ពុំគួរនឹងឲ្យឃ្លាតឆ្ងាយអំពីអម្ចាស់នោះទេ, កុំអម្ចាស់តាមដោយនូវពាក្យអ្នកស្រីពិរាស្ត្រនោះឡើយ ។

តំ សុត្វា រាជា អាហ ។ ព្រះបាទស្រីសញ្ជ័យ ទ្រង់ព្រះសណ្ដាប់ពាក្យព្រះនាងសុបារសុប្បតីនោះហើយ ទើបមានព្រះបន្ទូលដូច្នេះវិញថា ៖

ធម្មស្សាបចិតិំ កុម្មិំ សរីរំ វិជយំ ឌជំ
បញ្វាជេមិ សកំ បុត្តំ ចាណា បិយតរោ ហិ មេតិ ។

ហៃនាងសុបារសុប្បតីអើយ វីបាវេស្សន្តរនេះ ជាកូនកើតអំពីឧទរពិតនូវដោយធម៌ ប្រាកដជាស្រឡាញ់នៃអ្នកផង ដោយអ្នកផង

Websites: WatKhemaraRatanaram.org or WatKhmers.org

សឹងទុកជាត្រើយ ។ នាងអើ្វយ! បើអញទុកនៅឡើយ ហើយវា នឹងនាំអាស្រូវភាស បើអញមិនដោយតាមពាក្យអ្នកស្រីពិរាស្រ្តនោះ ឃើញជាគេមិនទុកជីវិតអញឡើយ ។

សា តំ សុត្វា បរិទេវមានា អាហ ។ ហៃសាធុសប្បុរសផងទាំងឡាយអើយ រីព្រះនាងសុបារសុប្បតីទេវី កាលបើបានស្តាប់ព្រះរាជបន្ទូលព្រះបាទស្រីសញ្ជ័យនោះហើយ ព្រះនាងតឹងរឹងតែព្រះកន្សែងយោបំច្រើនឡើងទៀតថាដូច្នេះ

យស្ស បុព្វេ ធជគ្គានិ កណិការាវ បុប្ផិតា
យាយន្តមនុយាយន្តិ ស្វជ្ជេកោវ គមិស្សតិ ។
យស្ស បុព្វេ ធជគ្គានិ កណិការវនានិវ
យាយន្តមនុយាយន្តិ ស្វជ្ជេកោវ គមិស្សតិ ។
យស្ស បុព្វេ អនីកានិ កណិការាវ បុប្ផិតា
យាយន្តមនុយាយន្តិ ស្វជ្ជេកោវ គមិស្សតិ ។
យស្ស បុព្វេ អនីកានិ កណិការវនាន
យាយមន្តមនុយាយន្តិ ស្វជ្ជេកោវ គមិស្សតិ ។

ឥន្ទគោបកវណ្ណាភា　គន្ធារា បណ្ឌុកម្ពលា
យាយន្តមនុយាយន្តិ　ស្វជ្ជេកោវ គមិស្សតិ។
យោ បុព្វេ ហត្ថិនា យាតិ　សិវិកាយ រថេន ច
ស្វជ្ជ វេស្សន្តរោ រាជា　កថំ គច្ឆតិ បត្តិកោ។
កថំ ចន្ទនលិត្តង្គោ　នច្ចគីតប្បពោធនោ
ខុរាជិនំ ផរសុញ្ច　ខារិកាជញ្ច ហារិតិ។
កស្មា នាភិហរីយន្តិ　កាសាវា អជិនានិ ច
បវិសន្តំ ព្រហារញ្ញំ　កស្មា ចីរំ ន ពជ្ឈរេ។
កថំ ន ចីរំ ធារេន្តិ　រាជបព្វជិតា ជនា
កថំ កុសមយំ ចីរំ　មទ្ទី បរិទហិស្សតិ។
កាសិយានិ ច ធារេត្វា　ខោមកោដុម្ពរានិ ច
កុសចីរានិ ធារេន្តី　កថំ មទ្ទី ករិស្សតិ ។
វយ្ហាហិ បរិយាយិត្វា　សិវិកាយ រថេន ច
សា កថជ្ជ អនុជ្ជង្គី　បថំ គច្ឆតិ បត្តិកា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

យស្សា មុទុតលា ហត្ថា    ចលណា ច សុខេ ធិតា
សា កាថជ្ជ អនុច្ចង្គី    បជំ គច្ឆតិ បត្តិកា។
យស្សា មុទុតលា បាទា    ចលណា ច សុខេ ធិតា
បាទុកាហិ សុវណ្ណាហិ    បីឡមានា គច្ឆតិ។
សា កាថជ្ជ អនុច្ចង្គី    បជំ គច្ឆតិ បត្តិកា
យស្សុ ឥត្ថីសហស្សស្ស    បុរតោ គច្ឆតិ មាលិនី។
សា កាថជ្ជ នុច្ចង្គី    វនំ គច្ឆតិ ឯកិកា
យា សា សិវាយ សុត្វាន    មុហុំ ឧត្តសតេ បុរេ ។
សា កាថជ្ជ អនុច្ចង្គី    វនំ គច្ឆតិ ភីរុកា
យា សា ឥន្ទសគោត្តស្ស    ឧលូកស្ស បវស្សតោ។
សុត្វាន នទតោ ភីតា    វារុណីវ បវេធតិ
សា កាថជ្ជ អនុច្ចង្គី    វនំ គច្ឆតិ ភីរុកា។
សកុណី ហតបុត្តាវ    សុញ្ញំ ទិស្វា កុលាវកំ
ចិរំ ទុក្ខេន ឈាយិស្សំ    សុញ្ញំ អាគម្មិមំ បុរំ ។

សកុណី ហាតបុត្តារ    សុញ្ញំ ជិសា កុលាវកំ
កីសា បណ្ឌុ ភរិស្សាមិ    បិយេ បុត្តេ អបស្សតី ។
សកុណី ហាតបុត្តារ    សុញ្ញំ ជិស្វា កុលាវកំ
តេន តេន បជាវិស្សំ    បិយេ បុត្តេ អបស្សតី ។
កុររី ហាតច្ឆាចារ    សុញ្ញំ ជិស្វា កុលាវកំ
ចិរំ ទុក្ខេន ឈាយិស្សំ    សុញ្ញំ អាគម្មិមំ បុរំ ។
កុររី ហាតច្ឆាចារ    សុញ្ញំ ជិស្វា កុលាវកំ
កីសា បណ្ឌុ ភរិស្សាមិ    បិយេ បុត្តេ អបស្សតី ។
កុររី ហាតច្ឆាចារ    សុញ្ញំ ជិស្វា កុលាវកំ
តេន តេន បជាវិស្សំ    បិយេ បុត្តេ អបស្សតី ។
សា នូន ចក្កាវក្កីវ    បល្លលស្មឹ អនូទកេ
ចិរំ ទុក្ខេន ឈាយិស្សំ    សុញ្ញំ អាគម្មិមំ បុរំ ។
សា នូន ចក្កាវក្កីវ    បល្លលស្មឹ អនូទកេ
កីសា បុណ្ឌ ភរិស្សាមិ    បិយេ បុត្តេ អបស្សតី ។
សា នូន ចក្កាវក្កីវ    បល្លលស្មឹ អនូទកេ
តេន តេន បជាវិស្សំ    បិយេ បុត្តេ អបស្សតី ។

ឯវំ មេ វិលបន្តិយា ... រាជបុត្តំ អនុសក្កំ
បញ្ចាជេសិ ច នំ រដ្ឋា ... មញ្ញេ ហេស្សាមិ ជីវិតន្តិ ។

បពិត្រព្រះបាទស្រីសញ្ជ័យជាអម្ចាស់ខ្ញុំអើយ! វិបាវេស្សន្តរដ៏ជាព្រះរាជបុត្រ ទ្រង់មានដំណើរទៅកាន់ឋានឯណានីមួយ សឹងដ៏ប្រកបដោយពួកពលសកលយោធា សេនាទាហាន មានទាំងនាយដំរី នាយសេះ នាយរទេះ នាយពាជីរាជរថ នាយពលថ្មើរជើងផងទាំងឡាយនោះ សឹងដ៏ប្រកបនូវសំលៀកបំពាក់ មានពណ៌នោះស្រស់ៗ ផ្សេងៗ ខ្លះស្លៀកស, ខ្លះស្លៀកខ្មៅ, ខ្លះស្លៀកលឿង ដ៏មានពណ៌នោះល្អ ដូចខ្នងអណ្តើកមាស ដែលហើរទៅមកក្រោមដើមកណ្ណិការ ដ៏មានផ្ការីកស្គុសស្គាយ ។ មួយសោត បាវេស្សន្តរជាអ្នកតែងស្លៀកនូវសំពត់រត្តកម្ពល ដ៏មានពណ៌នោះល្អបីដូចផ្កាចារ ហើយហែហមអមដោយសងខាង ទៅលេងនាព្រៃឧទ្យាននាកាលមុនមិញ ក៏ឥឡូវនេះបាវេស្សន្តរ នឹងទៅត្រមោចតែម្នាក់ឯង ដើរទៅតែជើងទទេ ដោយនូវផ្លូវនោះដូចម្តេចបាន ។

បាវេស្សន្តរអើយ បើនឹងទៅលេងឯណានោះ រមែងតែជិះ

Websites: WatKhemaraRatanaram.org or WatKhmers.org

ដំរី ជិះសេះ ជិះរាជរថ បរទៅលេងឯព្រៃឧទ្យាន កំសាន្តព្រះទ័យនាកាលមុនមិញ ឥឡូវនេះនឹងដើរទៅតែជើងទទេម្នាក់ឯង ដោយនូវផ្លូវនោះហោង ។

ឱ! បាវេស្សន្តរអើយ អ្នកធ្លាប់តែងលាប នូវសុគន្ធពិដោរជាដើម គឺលំអិតខ្លឹមច័ន្ទន៍ក្រស្នា ក្លាំពាក់ក្លាំពា ឈ្មុសទេសម្ប្រៅ ធ្លាប់នៅស្រណុកពុំដែលស្គាល់ទុក្ខ តែងទ្រង់ស្តាប់នូវសូរស័ព្ទភ្លេងតូរ្យតន្ត្រី របាំ ចម្រៀងផងទាំងឡាយ ឥឡូវនេះម្តេចឡើយ ក៏ទៅស្លៀកឯសំពត់សំបកឈើ គឺអ្នកក្រងនីទៅនូវស្បូវភ្លាំង ហើយស្ពាយផៀងស្បែកខ្លាឃ្មុំទាំងក្រចក ទ្រង់នូវញើសក្អែល ចូលទៅក្នុងអំឡុងព្រៃធំនោះតែម្នាក់ឯង ។

ឱ! អញអើយ បើដូចជាអញគិតនេះហើយ នាបីហៅថាជាកូនស្តេច ដែលគេបំបរបង់ចេញពីស្រុក ទៅនៅនាព្រៃនោះ ទោះធ្លាប់តែស្លៀកសំពត់កាសិកពស្ត្រ កោទុម្ពរពស្ត្រ ខោមពស្ត្រ ធ្លាប់នៅស្រណុកយ៉ាងណា ក៏ឥឡូវនេះនឹងទៅនៅជាទុក្ខនាក្នុងព្រៃនោះហោង។

ឱ! ដូចអញគិតនេះហើយ រីនាងមទ្រី ធ្លាប់តែនៅស្រណុក

Websites: WatKhemaraRatanaram.org or WatKhmers.org

ឥឡូវនេះ ក៏វែងទ្រង់នូវសំពត់កោសិកពស្ត្រ កោទុម្ពរពស្ត្រ ខោមពស្ត្រ ម្ដេចឡើយក៏នឹងទៅស្លៀក ឯសំពត់សំបក់ឈើ គិតដ៏អ្នកក្រុងនីទៅនូវស្បូវភ្លាំង ហើយទៅនៅនាក្នុងព្រៃនោះបាន ។

ឱ! ដូចអញគិតនេះហើយ រីនាងមទ្រី ថាបើនឹងទៅប្រពាតក្រសាលឯណា ៗ ក្ដី ធ្លាប់វែងជិះលើគ្រែស្នែង ជិះរាជរថឥឡូវនេះ ម្ដេចឡើយ ក៏នឹងទៅតែជើងទទេ ដោយផ្លូវនោះបាន ។

ឱ! ដូចអញគិតនេះហើយ រីនាងមទ្រី មានចង្កេះរៀវក្លៀវក្លំសមនូវជើងដៃនោះទន់ល្វន់ល្វាស ធ្លាប់តែនៅស្រណុក ពុំដែលប្រសព្វនូវទុក្ខសោកទាំងអម្បាលនោះឡើយ ឥឡូវនេះនាងនឹងទៅតែជើងទទេ ឥតព្រះសុពណ៌បាទុក គ្រាន់នឹងជាទ្រនាប់ព្វដ៏ព្រះបាទនោះក៏នឹងដើរទៅឆ្ងាយពុំបានឡើយ ។

បពិត្រព្រះបាទស្រីសញ្ជ័យអើយ! រីនាងមទ្រី ថាបើនឹងនាងយាងទៅទីឯណា ៗ នោះ មានស្រីព្រះស្នំ ១ ពាន់ដើរនាំមុខ ១ ពាន់ដើរក្រោយ អម្ចាស់អើយ រីនាងមទ្រីធ្លាប់នៅស្រណុកជាមួយនឹងរាជបរិវារដូច្នេះ ឥឡូវនេះម្ដេចឡើយ នាងនឹងដើរទៅតែជើងទទេ តែម្នាក់

ឯងនៅក្នុងព្រៃនោះបាន ។

បពិត្រព្រះបាទស្រីសញ្ជ័យអើយ! រីនាងមទ្រី សព្វថ្ងៃនេះ នាងធ្លាប់តែនៅក្នុងព្រះរាជមន្ទីរ គ្រាន់ឮសម្រែកចចក តុកកែ ឆ្កែព្រៃក្តី មៀមមុំ ទីទុយ ខ្លែងខ្មោចក្តី សឹងដ៏មានខ្លួននោះញ័រចំប្រប់ បីដូចមត់បញ្ជាន់រូប ឥឡូវនេះម្តេចឡើយ នឹងទៅតែម្នាក់ឯង នៅនាព្រៃទុគ៌ម ជ្រងំស្ងាត់នោះបាន ។

បពិត្រព្រះបាទស្រីសញ្ជ័យអើយ! មេបក្សីទាំងឡាយក្រវើនតែរកចំណីនៅឯព្រៃឆ្ងាយ លះបង់កូនតូចនៅអាយ នាកន្ទ្រាមសំបុកនោះ អ្នកថ្មើរព្រៃផងទាំងឡាយ គេសម្លាប់កូននោះបង់ហើយ រីមេបក្សីយល់កន្ទ្រាមសំបុក ស្ងាត់បាត់កូននោះហើយ ជាទុក្ខច្រើនក្រៃម្តេចមិញ ។ រីឯអញខ្ញុំសោត ក៏នឹងកើតទុក្ខក្រៀមក្រំ យល់តែព្រះមន្ទីរនេះ ស្ងួនស្ងាត់បាត់កូនសម្លាញ់ ហើយក៏នឹងជាទុក្ខដូច្នោះហោង ។ មួយសោត បីដូចមេសត្វករវិក តែងនឹងហើររកចំណីចេញទៅព្រៃឆ្ងាយ គេយកកូនឯអាយ ហើយមកយល់តែកន្ទ្រាមសំបុកដ៏ស្ងាត់នោះ ជាទុក្ខច្រើនក្រៃម្តេចមិញ ឯអញខ្ញុំសោតមកយល់

Websites: WatKhemaraRatanaram.org or WatKhmers.org

តែព្រះរាជមន្ទីរ នោះសូន្យស្ងាត់បាត់កូនសម្លាញ់ទាំង ២ នឹងជាទុក្ខដូច្នោះហោង ។ មួយនីសោត បីដូចមេសត្វប្រវឹក តែងហើរទៅរកចំណីនៅព្រៃឆ្ងាយ គេយកពងឯអាយ ត្រឡប់មកយល់តែកន្ត្រាមសំបុក រកពង រកកូនមិញសូន្យស្ងាត់ បាត់ពុំឃើញសោះឡើយ រីមេសត្វនោះ ជាទុក្ខបម្រះនឿលនៅលើកន្ត្រាម សំបុកនោះម្ដេចមិញ ។ រីអញខ្ញុំសោត នឹងយល់តែព្រះរាជមន្ទីរនោះ សូន្យស្ងាត់បាត់កូនសម្លាញ់ទាំង ២ ក៏នឹងជាទុក្ខនៅក្នុងព្រះរាជមន្ទីរ បីដូច្នោះហោង ។ មួយនីសោត រីមេសត្វចាក្រពាក មេអក មេទុង មេហង្សមេក្រៀលក្ដី កាលណាបើបាក់ចំអេងរលីងស្លាប ដួលស្រប៉ាប់នៅលើភក់ តែងលំបាកតែម្នាក់ឯងម្ដេចមិញ អញខ្ញុំសោត ក៏ជាទុក្ខតែម្នាក់ឯងនៅក្នុងព្រះរាជមន្ទីរ មានឧបមាបីដូច្នេះហោង ។

ហៃសាធុសប្បុរសផងទាំងឡាយអើយ រីព្រះនាងសុបារសុប្បតីទេវី ទ្រង់ព្រះកន្សែងរៀបរាប់ដូច្នេះទៀតថា ហេតុអ្វីអើយ ក៏គេមកបំបរបង់បាវេស្សន្តរ ដ៏ជាអ្នកឥតទោស ដោយនូវពាក្យអ្នកស្រីពិរាស្ត្រនេះ ។ ឱ! ដូចអញគិតនេះហើយ ថាបើឥតនឹងបាវេស្សន្តរ

Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយ សមជីវិតអញក្ស័យមែនហោង ។

ហៃសាធុជនផងទាំងឡាយអើយ កាលណាព្រះនាងសុបារសុប្បតីទេវី ទ្រង់ព្រះកន្សែងឃោបំដូច្នោះហើយ ក្សិណនោះ រីអស់ស្រីព្រះស្នំក្រមការ បរិវារ បំរើទាំងអម្បាលម៉ាន នៅក្នុងព្រះរាជមន្ទីរនោះក្តី នៅក្រៅព្រះរាជមន្ទីរព្រះបាទស្រីវេស្សន្តរនោះក្តី កាលណាបើឮសព្ទឃោបំនៃព្រះនាងសុបារសុប្បតី ទ្រង់ព្រះកន្សែងហើយ រីអស់ស្រីស្នំទាំងអម្បាលនោះ សឹងមកជំនុំព្រមនឹងគ្នាហើយ សឹងធំលើកដៃដាក់លើត្បូង ដៃមួយគក់ទ្រូង ទួញយំសោកស្រណោះអាឡោះអាល័យ ក្សត្រថ្លៃទាំង ២ ព្រះអង្គនោះ ពុំអាចនឹងទប់ទល់តម្កល់អាត្មាភាពបានឡើយ សឹងធំមានខ្លួនញ័រចំប្រប់ សន្លប់ដួលទៅនៅនាព្រះរាជមន្ទីរ បីដូចព្រៃសាលវ័ន ដួលទៅដោយអំណាចខ្យល់បក់បំភ្លូកដូច្នោះហោង ។

**តមត្ថំ បកាសេន្តោ សត្ថា អាហ** ។ រីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គឈ្មោះមារ ស្តេចមានព្រះបន្ទូលសូត្រសា នូវបាទគាថាទាំងឡាយ ដូច្នេះថា ៖

Websites: WatKhemaraRatanaram.org or WatKhmers.org

តស្សា ឡាលបិតំ សុត្វា សព្វា អន្តេបុរេ អហុ
ពាហា បគ្គយ្ហ បក្កន្ទុំ សិវិកញ្ញា សមាគតា ។
សាឡាវ សម្បមទ្ទិតា មាលុតេន បមទ្ទិតា
សេដ្ឋិ បុត្តា ច ទារា ច វេស្សន្តរនិវេសនេ ។
ឱរោធា ច កុមារា ច វេសិយានា ច ព្រាហ្មណា
ពាហា បគ្គយ្ហ បក្កន្ទុំ វេស្សន្តរនិវេសនេ ។
ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា
ពាហា បគ្គយ្ហ បក្កន្ទុំ វេស្សន្តរនិវេសនេ ។
តតោ រត្យា វិវសនេ សុរិយស្សុគ្គមនំ បតិ
អថ វេស្សន្តរោ រាជា ទានំ ទាតុំ ឧបាគមិ ។
វត្ថានិ វត្ថកាមានំ សោណ្ឌានំ ទេថ វារុណឹ
ភោជនំ ភោជនត្ថីនំ សម្មទេវ បវេច្ឆថ ។
មា ច កិញ្ចិ វនិព្វកេ ហេឋយិត្ថ ឥធាគតេ
តប្បេថ អន្នបានេន គច្ឆន្តុ បដិបូជិតា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

តេ សុ មត្តា កិលន្តាវ　　សម្បតន្តិ វណិព្វកា

និក្ខមន្តេ មហារាជេ　　សិវីនំ រដ្ឋវឌ្ឍនេ ។

អច្ឆម្ភុំ វត ភោ រុក្ខំ　　នានាផលទទំ ទុមំ

យថា វេស្សន្តរំ រដ្ឋា　　បព្វាជេន្តិ អទូសកំ ។

អច្ឆម្ភុំ វត ភោ រុក្ខំ　　នានាផលធរំ ទុមំ

យថា វេស្សន្តរំ រដ្ឋា　　បព្វាជេន្តិ អទូសកំ ។

អច្ឆម្ភុំ វត ភោ រុក្ខំ　　សព្វកាមទទំ ទុំមំ

យថា វេស្សន្តរំ រដ្ឋា　　បព្វាជេន្តិ អទូសកំ ។

អច្ឆម្ភុំ វត ភោ រុក្ខំ　　សព្វកាមរសាហរំ

យថា វេស្សន្តរំ រដ្ឋា　　បព្វាជេន្តិ អទូសកំ ។

យេ វុឌ្ឍា យេ ច ទហរា　　យេ ច មជ្ឈិមបោរិសា

ពាហា បគ្គយ្ហ បក្កន្ទុំ

និក្ខមន្តេ មហារាជេ　　សិវីនំ រដ្ឋវឌ្ឍនេ ។

អតិយក្ខា វេស្សវរា　　ឥត្ថាគារា ច រាជិនោ

Websites: WatKhemaraRatanaram.org or WatKhmers.org

## ពាហា បគ្គយ្ហ បក្កន្ទុំ

និក្ខមន្តេ មហារាជេ  សិវីនំ រដ្ឋវឌ្ឍនេ ។
ថិយោបិ តត្ថ បក្កន្ទុំ  យា តម្ហិ នគរេ អហុ
និក្ខមន្តេ មហារាជេ  សិវីនំ រដ្ឋវឌ្ឍនេ ។
យេ ព្រាហ្មណា យេ ច សមណា អញ្ញេ វាបិ វនិព្វកា
ពាហា បគ្គយ្ហ បក្កន្ទុំ  អធម្មោ កិរ ភោ ឥតិ ។
យថា វេស្សន្តរោ រាជា  យជមានោ សកេ បុរេ
សិវីនំ វចនត្ថេន  សម្ហា រដ្ឋា និរជ្ជតិ ។
សត្ត ហត្ថិសតេ ទត្វា  សព្វាលង្ការភូសិតេ
សុវណ្ណកច្ឆេ មាតង្គេ  ហេមកប្បនីវាសសេ ។
អារុឡ្ហេ គាមណីយេភិ  តោមរង្កុសបាណិភិ
ឯស វេស្សន្តរោ រាជា  សម្ហា រដ្ឋា និរជ្ជតិ ។
សត្ត អស្សសតេ ទត្វា  សព្វាលង្ការភូសិតេ
អាជានិយេវ ជាតិយា  សិន្ធវេ សីឃវាហនេ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អារុឡ្ហា គាមណីយេភិ ឥន្ទិយាចាបធារិភិ
ឯស វេស្សន្តរោ រាជា សម្កា រដ្ឋា និរជ្ជតិ ។
សត្ត រថសតេ ទត្វា សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ សព្វាលង្ការភូសិតេ ។
អារុឡ្ហា គាមណីយេភិ ចាបហត្ថេហិ ចម្មិភិ
ឯស វេស្សន្តរោ រាជា សម្ហា រដ្ឋា និរជ្ជតិ ។
សត្ត ឥត្ថីសតេ ទត្វា ឯកមេកា រថេ ឋិតា
សន្នទ្ធា និក្ខរជ្ជូហិ សុវណ្ណេហិ អលង្កតា
បីតាលង្ការា បីតវសនា បីតាភរណភូសិតា
អឡារប្បមុខា ហសុលា សុសញ្ញា តនុមជ្ឈិមា
ឯស វេស្សន្តរោ រាជា សម្ហា រដ្ឋា និរជ្ជតិ ។
សត្ត ធេនុសតេ ទត្វា សព្វា កំសុបធារិណោ
ឯស វេស្សន្តរោ រាជា សម្ហា រដ្ឋា និរជ្ជតិ ។
សត្ត ទាសីសតេ ទត្វា សត្ត ទាសសតានិ ច

Websites: WatKhemaraRatanaram.org or WatKhmers.org

ឯស វេស្សន្តរោ រាជា    សម្ហា រដ្ឋា និរជ្ជតិ ។
ហត្ថី អស្សេ រថេ ទត្វា    ជារិយោ ច អលង្កតា
ឯស វេស្សន្តរោ រាជា    សម្ហា រដ្ឋា និរជ្ជតិ ។
តទាសិ យំ ភឹសនកំ    តទាសិ លោមហំសនំ
មហាទានេ បទិន្នម្ហិ    មេទនី សមកម្បថ ។
តទាសិ យំ ភឹសនកំ    តទាសិ លោមហំសនំ
យំ បញ្ជលីកតោ រាជា    សម្ហា រដ្ឋា នរជ្ជតីតិ ។

ហៃភិក្ខុផងទាំងឡាយអើយ រីអស់អ្នកទាំងអម្បាលណោះ ដែលមាននៅក្នុងកំឡុងព្រះនគរនោះក្តី ទោះស្រីស្នំក្រមការ អ្នកបំរើនោះក្តី ទោះកូនអាមាត្យក្តី ទោះជាព្រះរាជបុត្រក្តី ទោះអ្នកឈ្មួញជួញប្រែក្តី ទោះព្រាហ្មណ៍ព្រឹទ្ធ បណ្ឌិតកវី អ្នកប្រាជ្ញក្តី មិនប៉ុន្តែម្ល៉ោះឡើយ ទោះនាយដំរី នាយរទេះ នាយពាជី នាយរាជរថ នាយពលថ្មើរជើងក្តី ទោះអ្នកស្រុកក្រៅលំនៅជនបទផងទាំងឡាយក្តី រីអ្នកទាំងអម្បាលណោះ កាលណាបើឮសព្ទឃោបំ សម្លេងទ្រង់ព្រះកន្សែង នៃព្រះនាងសុបារសុប្បតីទេវីហើយ ក៏ពុំអាចដើម្បីទប់ទល់ តម្កល់អាត្មាភាពនោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

បានឡើយ សឹងដ៏លើកដៃដាក់លើត្បូង ដៃមួយគក់ទ្រូងទូញយំ ដ៏មានសព្ទសម្លងនោះមហិមាក្រៃពេក មុខគួរឲ្យខ្លាច មានឮដ៏ស្រុកជេតុតគួរនគរនោះហោង ។

ហៃសាធុសប្បុរសផងទាំងឡាយអើយ អណ្តាប់នោះ ព្រះអាទិត្យរះភ្លឺឡើងហើយក្ងរ ព្រះមហាសត្វស្តេចដោះឡើងកក់ជម្រះព្រះកាយស្រង់ស្រេចហើយ ទ្រង់នូវគ្រឿងប្រដាប់សព្វប្រការ ហើយស្តេចសោយភោជនាហារ ដ៏មានរសពិសាផ្សេងៗ ទើបស្តេចលីលាទៅកាន់សាលាទានមួយអន្លើ នឹងអាមាត្យផងទាំងឡាយជាបរិវារស្តេចមានព្រះចំណង់ចង់ឲ្យសត្តសតកមហាទាន ។

ភិក្ខុអើយ នាកាលបើអំណើះ ដំណើរព្រះអាទិត្យរះឡើងហើយនោះ ក្សិណនោះព្រះបាទស្រីវេស្សន្តរ ដ៏ជាក្សត្រដ៏ប្រសើរស្តេចទៅកាន់សាលាទានមួយអន្លើ នឹងអស់អាមាត្យទាំង ៦ ម៉ឺនក្ងរទ្រង់ឲ្យរណ្តាប់ទាន នឹងឲ្យស្នូមយាចកផងទាំងឡាយដូច្នេះថា «ហៃអាមាត្យអើយ ថាបើស្មូមឯណាមួយ វាមកសាលាទាននេះហើយបើវាចង់បានសំពត់ ក៏ចូរប្រស្វែងរណ្តាប់សំពត់ឲ្យជាទានស្នូមនោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

ហោង ។ បើស្មូមឯណាមួយ វាចង់ហូបបាយក្តី ចូរប្រស្វែងរណ្តាប់បាយ ឲ្យស្មូមនោះហូបឲ្យឆ្អែត ហើយឲ្យទានតាមចំណង់ចិត្តស្មូមនោះហោង›› ។

ហែសប្បុរសផងទាំងឡាយអើយ រីព្រះបាទស្រីវេស្សន្តរដ៏ជាក្សត្រប្រសើរ តែងទ្រង់ចម្រើនអ្នកស្រុកស្រីពិរាស្ត្រ ។ ស្តេចឲ្យទានស្រេច ព្រះអង្គនឹងចេញទៅពីស្រុកជេតុត្តរនគរ កាលឯណាកូវឯស្មូមផងទាំងឡាយមកទទួលយកព្រះរាជទានហើយ ក៏បបួលគ្នាមកឈរជាចំពូកៗ ហើយស្រដីដូច្នោះថា ៖

ភោន្តោ ម្នាលគ្នាយើងទាំងឡាយអើយ រីព្រះបាទស្រីវេស្សន្តរនេះ ជាពំនាក់អស់ស្មូមផងទាំងឡាយ ឧបមាបីដូចអ្វីថា, ឧបមាបីដូចដើមឈើណាមួយមានផ្លែផ្កា ដ៏ជាពំនាក់នៃសត្វផងទាំងឡាយ វាហើរមកពីចម្ងាយ វាឃ្លានបាយចំណី ក៏ចង់បរិភោគឲ្យទាល់តែឆ្អែត ។

ឱ ! ព្រះបាទស្រីវេស្សន្តរអើយ ព្រះអង្គហោងជាអ្នកឥតទោស ហេតុអ្វីអើយ ក៏អ្នកស្រីពិរាស្ត្រ មកបំបរបង់ព្រះអង្គឲ្យខ្វាយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ចេញពីស្រុកដូច្នេះ ។

ភោន្តោ ម្នាលគ្នាយើងទាំងឡាយអើយ រីអ្នកស្រីពិរាស្រ្ត នេះ ឧបមាបីដូចអ្នកកន្រ្ទឹសឫស្សា មកកាប់ដើមឈើសឹងដ៏មានផ្លែផ្កា សឹងជាទីពំនាក់នៃសត្វផងទាំងឡាយនោះ ឲ្យអន្តរាយ ពុំឲ្យសត្វផង ទាំងឡាយនេះពឹងបានឡើយ ។ ឱ! ព្រះវេស្សន្តរជាអ្នកឥតទោស ជាពំនាក់នៃស្មូមផងទាំងឡាយ ទោះស្មូមឯណានឹងប្រាថ្នាអ្វីៗ ក៏ ទ្រង់ឥតទើសទ័លសល់ក្រអ្វីឡើយ ។

ឱ ! អ្នកទាំងឡាយអើយ ទោះអ្នកឯណាមួយ ទោះក្មេង ពាលកណ្តាលចាស់នោះ តែបានមកដល់ហើយ មានប្រាថ្នាត្រង់ ឯណាមិញ សឹងបានដូចបំណងត្រង់ណោះហោង ។ ឱ ! អ្នកទាំង ឡាយអើយ អំពីថ្ងៃនេះទៅហើយ រីស្មូមផងទាំងឡាយ ឥតបីពំនាក់ ឡើយ ។ រីស័ព្ទឃោបំនេះ មិនប៉ុន្តែស្មូមនោះឡើយ ទោះអ្នកផ្ទួល មេមត់ក្តី ទោះអ្នកក្រៅលំនៅជនបទក្តី អ្នកចេះរក្សាភូមិផ្ទៃក្រោមក្តី អ្នក ថែទាំចាំឃ្លាំងចាំវាំងក្តី ព្រះរាជមន្ទីរក្តី ទោះស្រីព្រះស្នំក្រមការ អ្នក បំរើក្តី ទោះព្រាហ្មណ៍ព្រឹទ្ធ បណ្ឌិតកវីក្តី រីអស់អ្នកអម្បាលណោះ សឹង

មកជំនុំគ្នា សឹងលើកដៃដាក់លើត្បូង ដៃមួយគក់ទ្រូងទួញយំ សឹងព្ទស័ព្ទឃោឃំយំនោះច្រើនមហិមាថា "ឱ!អ្នកទាំងឡាយអើយ រីអ្នកស្រីពិរាស្រ្តផងទាំងឡាយនេះ ហៅថាជាអ្នកឥតធម៌ពិតហោង" ។ ម្តេចឡើយក៏មកបំបរបង់ ព្រះបាទស្រីវេស្សន្តរ ជាអ្នកឥតទោសឲ្យប្រាសនិរាសចេញពីស្រុកដូច្នេះ ។

ឱ ! ព្រះបាទស្រីវេស្សន្តរក្សត្រថ្លៃប្រសើរ នៃយើងខ្ញុំទាំងឡាយអើយ ឥឡូវនេះព្រះអង្គនៅតែឲ្យទាន ហើយស្តេចនឹងចេញទៅពីស្រុកនេះ ដោយនូវពាក្យអ្នកស្រីពិរាស្រ្តគេបំបរបង់នោះហោង ។

រីព្រះបាទស្រីវេស្សន្តរ ដ៏ក្សត្រប្រសើរនោះ ស្តេចឲ្យទានមានដំរីនោះ ៧០០ រយ រីដំរីនោះសោត សឹងប្រដាប់នីទៅនូវខ្សែក្រពាត់លំយ៉ាង សំអាងមុខ ស្រោមភ្លុកសឹងដ៏មាស ដ៏មានកម្រាលលើខ្នងនោះសោត ដ៏ល្អនីទៅនូវកែវសព្វពិធវ័ត្ន រីទម័ក នោះសោតសឹងដ៏ពាក់នីទៅនូវម្ជុកមាស ខោស្នាប់ភ្លៅ ក្រោះក្រាយ រាយផ្កាយមាសទាំងពួង ដ៏មានដៃកាន់នីទៅនូវកង្វេរមាស ហើយឲ្យឡើងជិះព្រមគ្នា ទើបស្តេចលើកឲ្យទៅជាទាន ហើយស្តេចចេញទៅដោយនូវ

Websites: WatKhemaraRatanaram.org or WatKhmers.org

ពាក្យអ្នកស្រីពិរាស្ត្រនោះហោង ។

វិព្រះមហាក្សត្រ ព្រះអង្គឲ្យសេះ ៧០០ វីសេះនោះសោត ប្រដាប់នូវគ្រឿងទាំងពួង សឹងជាសេះអាជានេយ្យប្រសើរ សឹងកើតអំពីសិន្ធវៈប្រទេស មានកម្លាំងនោះស្មើខ្យល់ វីទម្រ័កសេះនោះសោត មានក្បាលពាក់មួក ដ៏មានដៃកាន់រំពាត់ផ្តៅ កៅទ័ណ្ឌ ហើយឡើងជិះព្រមគ្នាហើយ ស្ដេចលើកឲ្យទៅ ជាទានស្រេចបរិបូណ៌ពុំយូរឡើយ ទើបស្ដេចចេញទៅដោយនូវពាក្យអ្នកស្រីពិរាស្ត្រនោះហោង ។

ព្រះមហាក្សត្រព្រះអង្គឲ្យទានជារាជរថ ៧០០ ដ៏ប្រដាប់នូវកម្រាលចៀមចំ ព្រៃព្រាំដេរដាស ពាសពេញ នីទៅនូវស្បែកខ្លាឃ្មុំ ស្បែករាជសីហ៍ សំយាកទាំងសងខាង វីទ្រពងនោះសោតសឹងបណ្ដាញមាស ហើយមានចងចង្រ្កង់នាគ ប្រដាប់នូវត្បូងនោះសោត សឹងមាស វីនាយរាជរថនោះសោត ដ៏ប្រដាប់នូវគ្រឿងផ្ទិមអម្ពរ ដ៏មានដៃកាន់នូវគ្រឿងធ្នូសេលោហ៍ ក្បាលពាក់មួកហើយឡើងជិះព្រមគ្នា ស្ដេចលើកឲ្យជាទានស្រេចហើយ ស្ដេចចេញទៅដោយនូវពាក្យអ្នកពិរាស្ត្រដែលគេបំបរបង់នោះហោង ។ ស្ដេចឲ្យជាទានស្រីព្រះស្នំ

Websites: WatKhemaraRatanaram.org or WatKhmers.org

នោះ ៧០០ រីស្រីព្រះស្នំទាំងនោះសោត ឲ្យជិះលើរាជរថមួយៗ គ្រប់រាជរថ រីស្រីព្រះស្នំអស់នោះសឹងដ៏មានរូបនោះល្អ ប្រដាប់ដោយនីទៅនូវមកុដអារាម សឹងដ៏ទ្រង់នីទៅនូវគ្រឿងអម្ពរ រំលេចរចនាសឹងមាស សឹងដ៏មានចង្កេះរៀវក្លៀវក្លំ សមនូវបង្គុយនោះរាបសុភាពមានមាត់នោះញញឹមប្រិមប្រិយ ហើយបើនឹងហាស្រដីវិស័យស្រីទេពអប្សរនៅនាត្រៃត្រិង្សស្ថគ៌ មុខគួរតែចាំបំរើព្រះមហាក្សត្រនោះហោង ។

ហៃសប្បុរសជនផងទាំងឡាយអើយ មិនប៉ុន្តែម្ល៉ោះឡើយព្រះអង្គឲ្យទានខ្ញុំស្រីនោះ ៧០០ ខ្ញុំប្រុសនោះ ៧០០, ព្រះអង្គឲ្យទានគោបាព្រោះនោះ ៧០០ មេគោឆ្នាត់នោះ ៧០០ នូវអាងតែងរងក្បីរសឹងមាសនោះ ៧០០ ។ ស្រេចហើយទើបព្រះអង្គស្តេចចេញទៅដោយនូវពាក្យអ្នកស្រីពិរាស្រ្តនោះហោង ។

ហៃសាធុសប្បុរសផងទាំងឡាយអើយ រីព្រះពោធិសត្វ ព្រះអង្គឲ្យទានស្រេចហើយ ព្រះអង្គប្រាថ្នាយកប្រាជ្ញាសព្វេជ្ញតាញាណទុកជាចំណងកាលណាមិញ រីពន្លឹកស័ព្ទអស្ចារ្យមហិមាក្រៃពេក ក៏កក្រើករំពើកទៅដល់អស់ទេពនិករអមរផង ដ៏មានខ្លួនញ័រចំប្រប់ ព្រឺ

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រួចអស់លោមា កើតមាននៅនាជេតុត្តរនគរ ឮដ៏កាលណោះហោង ។

តទា បន ទេវតា ជម្ពូទីបតលេ រាជូនំ វេស្សន្តរោ រាជា ខត្តិយកញ្ញាជិកំ មហាទានំ ទេតីតិ អារោចយិំសុ ។

ហៃសាធុសប្បុរសផងទាំងឡាយអើយ នាកាលព្រះមហាក្សត្រអ្នកឲ្យសត្តសតកមហាទាននោះ ទោះបីទេវតានៅនាឆកាមាវចរសួគ៌នាយក្តី ទោះបីទេវតាឋិតនៅជម្ពូទ្វីបផ្ទៃក្រោមនោះក្តី សឹងមកជ្រោមជ្រែងជួយបំពេញទាន នៃព្រះបរមពោធិសត្វ រីអស់ទេវតាទាំងនោះ ទៅស្រដីឃោសនា ប្រាប់អស់ព្រះមហាក្សត្រនៅនាជម្ពូទ្វីបនោះថា ភោន្តោ ម្នាលអស់ស្តេចផងទាំងឡាយអើយ ឥឡូវនេះព្រះបាទស្រីវេស្សន្តរ ព្រះអង្គឲ្យសត្តសតកមហាទាន ប្រដាប់នូវស្រីស្នំក្រមការនោះល្អៗ, សូមអញ្ជើញអ្នកទៅទទួលយកទាន នៃព្រះបាទស្រីវេស្សន្តរនោះហោង។

ហៃអស់សប្បុរសផងទាំងឡាយអើយ ហេតុតែអានុភាពទេវតាឃោសនានោះក្ងរ អស់ស្តេចផងទាំងឡាយ ក៏មកទទួលយកស្រីកញ្ញាអំពីព្រះមហាក្សត្រ ដែលឲ្យជាទាននោះ នាំទៅកាន់ឋាន

លំនៅអាត្មាទីទៃៗ ទៅហោង ។ បពិត្រអើយ រីអស់អ្នកផងទាំងពួងអម្បាលម៉ាន នៅនាជេតុត្តរនគរនោះ ទោះស្តេចក្តី ព្រាហ្មណ៍ក្តី ឈ្មួញក្តី អស់អ្នកទាំងអម្បាលនោះ សឹងមកទទួលយកទាននោះ ថាដូច្នេះ បពិត្រព្រះវេស្សន្តរអើយ រីអស់អ្នកស្រីពិរាស្រ្តផងទាំងឡាយ គេបំបរបង់អម្ចាស់ បទតែឲ្យទាននេះឯង ក៏អម្ចាស់រឹងជាឲ្យទានមួយសាសោតហោង ។

កាលណាព្រះអង្គឲ្យទានស្រេចហើយ លុះថ្ងៃល្ងាចស្តេចចូលទៅនាព្រះរាជមន្ទីរព្រះអង្គហើយ ព្រះអង្គទ្រង់ចិន្តាថា «នៅថ្ងៃស្អែកនេះឯង អញនឹងទៅថ្វាយបង្គំលា ព្រះវរមាតាបិតាអញ» ។

បុនទិវសេ មហាសត្តោ ។ រីព្រះមហាសត្វ លុះព្រឹកឡើងស្តេចឡើងគង់លើរាជរថ គិតដ៏អ្នកប្រដាប់ដ៏ប្រសើរ ក្បិណនោះ សម្តេចព្រះរាជមទ្រី ទ្រង់ពព្រះរាជកុមារទាំង ២ ទៅគង់លើរាជរថ ដើម្បីនឹងស្តេចទៅកាន់មេក្មេក បាក្មេក សូមឲ្យអ្នកអនុញ្ញាតឲ្យដំណើរទៅនឹងព្រះបាទស្រីវេស្សន្តរនោះហោង ។

មហាសត្តោ បិតរំ វន្ទិត្វា អត្តនោ គមនភាវំ កថេសិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

រីព្រះមហាសត្វ ស្តេចថ្វាយបង្គំលាព្រះវររាជមាតាបិតា ក្រាបទូល ដោយដំណើរស្តេចទៅនោះហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបាន ត្រាស់ហើយ ព្រះអង្គឈ្មោះនូវមារាធិរាជ អាចមានព្រះបន្ទូលនូវបាទ ព្រះគាថាដូច្នេះថា ៖

អាមន្តយិត្ថ រាជានំ សញ្ជយំ ធម្មិកំ វរំ
អវរុទ្ធសិ មំ ទេវ វង្កំ គច្ឆាមិ បព្វតំ ។
យេ ហិ កេចិ មហារាជ ភូតា យេ ច ភវិស្សរេ
អតិត្តាយេវ កាមេហិ គច្ឆន្តិ យមសាធនំ ។
សោហំ សកេ អភិសសឹំ យជមានោ សកេ បុរេ
សិវីនំ វចនត្ថេន សម្ហា រដ្ឋា និរជ្ជហំ ។
អឃន្តំ បដិសេវិស្សំ
វនេ វាឡមិគាកិណ្ណេ ខគ្គទីបិនិសេវិតេ

Websites: WatKhemaraRatanaram.org or WatKhmers.org

អហំ បុញ្ញានិ ការេមិ តុម្ហេ បជ្ជថ្វិ សីឧជាតិ ។

ភិក្ខុអើយ រីព្រះបាទស្រីវេស្សន្តរ កាលណាស្តេចនឹងចេញពីជេតុត្តរនគរនោះ ព្រះអង្គក្រាបទូលព្រះបាទស្រីសញ្ជ័យ ដែលព្រះអង្គតែងសោយរាជ្យ ឋិតនៅដោយគន្លងធម៌ដ៏ប្រសើរថា បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ ព្រះអង្គបំបរបង់អញខ្ញុំចេញ ក៏អញខ្ញុំនឹងចេញទៅសាងព្រះផ្នួស បួសនៅនាភ្នំវង្កតបព៌តនោះឯងហោង ។ បពិត្រព្រះមហារាជ ដ៏ជាស្តេចធំប្រសើរអើយ បើអ្នកឯណាមួយកើតឡើងឰដ៏លោកនេះ ចំពាក់នឹងកាមគុណហើយ ក៏អ្នកនោះឯង នឹងលុះក្នុងចំណងព្រះយមរាជមិនខាន ។ អញខ្ញុំនឹងទៅទូន្មានអាត្មាខ្ញុំឯង ហើយនឹងសាងព្រះផ្នួសចំរើនមេត្តាភាវនា នោះនាភ្នំវង្កតបព៌ត ដោយហេតុអ្នកស្រីពិរាស្ត្រ គេបំបរបង់អញខ្ញុំហោង ។ បពិត្រព្រះមហាក្សត្រថ្លៃប្រសើរអើយ អញខ្ញុំនឹងនៅនាព្រៃនោះមួយអន្លើនឹងម្រឹគពាឡសាហាវជាដើមគឺ រាជសីហ៍ ដំរីព្រៃ ខ្លាធំ ខ្លាដំបងផង អញខ្ញុំនឹងសូត្រមន្តចំរើនភាវនា នៅនាព្រៃនោះ ។ បពិត្រព្រះជនកអើយ សូមឲ្យព្រះអម្ចាស់គង់នៅនារាជ្យសម្បត្តិ ជាសុខសប្បាយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ទៅហោង ។

ឥតិ មហាសត្តោ ឥមាហិ ចតូហិ គាថាហិ បិតរា សទ្ធឹ កថេត្វា មាតុ សន្តិកំ គន្ត្វា វន្ទិត្វា បព្វជ្ជំ អនុជានាបេន្តោ ។ ព្រះមហាសត្វទូលព្រះវរបិតា ដោយនូវព្រះគាថា ៤ ព្រះគាថានោះ ហើយ ស្ដេចក៏ក្រាបថ្វាយបង្គំលា ទៅកាន់សំណាក់ព្រះនាងសុបារ សុប្បតី ដ៏ជាព្រះវរមាតា ដើម្បីនឹងសូមទ្រង់អនុញ្ញាតផ្នួសនៃអាត្មា ដោយក្រាបទូលសូត្រនូវបាទព្រះគាថាដូច្នេះ ៖

អនុជានាហិ មំ អម្ម បព្វជ្ជា មម រុច្ចតិ
សោហំ សកេ អភិសសិំ យជមានោ សកេ បុរេ
សិវីនំ រថេនត្តេន សម្មា រជ្ជា និរជ្ជហំ ។

អយន្តំ បដិសេវិស្សំ

វនេ វាឡមិគាកិណ្ណេ ខគ្គទីបិនិសេវិតេ
អហំ បុញ្ញានិ ករោមិ វគ្គំ គច្ឆាមិ បព្វតន្តិ ។

បពិត្រព្រះវររាជមាតា ជាអម្ចាស់ខ្ញុំអើយ សូមទានអម្ចាស់ អនុញ្ញាតផ្នួសឲ្យខ្ញុំអញ ៗ គាប់ចិត្តនឹងផ្នួសនោះណាស់ អម្បាលអញ

Websites: WatKhemaraRatanaram.org or WatKhmers.org

ខ្ញុំធ្វើទានតែក្នុងប្រាសាទរបស់ខ្លួន នៅឈ្មោះថាជាអ្នកបៀតបៀនអ្នកស្រុក អ្នកនគរ ដូច្នេះអញខ្ញុំក្រាបទូលសូមលា ទៅនៅភ្នំវង្កតបពិតនាព្រៃព្រះហេមពាន្ត តាមពាក្យអ្នកស្រីពិរាស្រ្តផងទាំងឡាយ ។ អម្ចាស់អើយ រីឋានដ៏ពេញនីទៅនូវសព្វម្រឹគឃោរឃៅសាហាវពន្លឹកជាដើមគឺ រាជសីហ៍ ដំរីព្រៃ ខ្លាធំ ខ្លាដំបង រមាំង រមាស ទន្សោងគោព្រៃ អម្ចាស់អើយ ខ្ញុំនឹងទៅសាងផ្នួសបួសជាមហាឫសី យកសត្វអស់នោះជាគ្នា ខ្ញុំនឹងចំរើនមេត្តាភាវនារក្សាផ្នួសនៅហោង ។

តំ សុត្វា ផុស្សតី ទេវី អាហ ។ រីព្រះនាងសុបារសុប្បតីដ៏ជាអគ្គមហេសីនៃព្រះបាទស្រីសញ្ជ័យ ទ្រង់ស្តាប់ព្រះរាជបន្ទូលដូច្នេះហើយ មានសេចក្តីព្រឺព្រួច គ្រលួចក្នុងព្រះហឫទ័យ ត្រេកអរសាទរនឹងផ្នួសក្រៃពេក ក៏មានព្រះបន្ទូលនូវព្រះគាថាដូច្នេះ ៖

អនុជានាមិ តំ បុត្ត បព្វជ្ជា តេ សមិជ្ឈតុ
អយញ្ច មទ្ទី កល្យាណី សុសញ្ញា តនុមជ្ឈិមា
អច្ឆតំ សហ បុត្តេហិ កឹ អរញ្ញេ ករិស្សតីតិ ។

ហៃកូនស្ងួនសម្លាញ់មាសម្តាយអើយ រីត្រង់ផ្នួសនេះម្តាយ

Websites: WatKhemaraRatanaram.org or WatKhmers.org

នឹងអនុញ្ញាតឲ្យព្ទដ៏អ្នកហើយ បាអើយ ប៉ុន្តែនាងមទ្រីដ៏ជាស្រីប្រកបនូវលក្ខណាទាំងឡាយ ធ្លាប់តែនៅស្រណុកសប្បាយ ចូរបាឲ្យនាងនៅឯអាយនឹងម្តាយថែរក្សាកូន ។ បាអើយ នាងមទ្រីនេះ ជាស្រីមិនធ្លាប់ប្រសព្វនូវទុក្ខអ្វីមួយ ម្តេចឡើយនឹងទៅនៅនាព្រៃនោះបាន ។

វេស្សន្តរោ អាហ ។ រីព្រះបាទស្រីវេស្សន្តរ ស្តាប់ព្រះបន្ទូលព្រះវរមាតាហើយ ទ្រង់ទូលតបស្នងវិញថាដូច្នេះ ៖

ជាហំ អកាមា ទាសឹបិ អរញ្ញំ នេតុមុស្សហេ
សចេ ឥច្ឆតិ អន្វេតុ សចេ និច្ឆតិ អច្ឆតុតិ ។

បពិត្រព្រះមាតាអម្ចាស់ខ្ញុំអើយ កុំថាតែនាងមទ្រីឡើយ ទោះដល់ខ្ញុំឯណាមួយ វាចង់ទៅនឹងអញខ្ញុំ ក៏អញខ្ញុំនឹងយកវាទៅនាព្រៃនោះ ថាបើវាមិនចង់ទៅសោត ក៏ឲ្យវានៅហោង ។ រីនាងមទ្រីសោត ថាបើនាងមិនចង់ទៅឡើយ ក៏នឹងឲ្យនាងនៅនឹងអម្ចាស់ឯអាយរក្សាកូនទាំង ២ ហោង ។

តតោ រាជា បុត្តស្ស កាថំ សុត្វា សុណ្ហំ យាចិតុំ បដិបន្នោ ។ ព្ទដ៏កាលណោះ ព្រះបាទស្រីសញ្ជ័យ ជាព្រះវររាជបិតា

Websites: WatKhemaraRatanaram.org or WatKhmers.org

ទ្រង់បានព្រះសណ្តាប់ស័ព្ទព្រះវាចា របស់ព្រះរាជបុត្រដូច្នោះហើយ ទើបស្តេចបែរទៅមានព្រះបន្ទូលលួងលោម សម្តេចព្រះនាងមទ្រី ដ៏ជាព្រះរាជបុត្រីប្រសាវិញ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះអង្គបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសានូវគាថាដូច្នេះ ៖

តតោ សុណ្ហំ មហារាជា យាចិតុំ បដិបជ្ជថ
មា ចន្ទនសមាចារេ រជោជល្លំ អធារយិ ។
កាសិយានិ បធារេត្វា កុសចីរំ អធារយិ
ទុក្ខោ វាសោ អរញ្ញស្មឹ មា ហិ ត្វំ លក្ខណេ គមីតិ ។

ភិក្ខុអើយ រីព្រះបាទស្រីសញ្ជ័យ ដ៏ជាស្តេចធំប្រសើរនោះ មានព្រះបន្ទូលនឹងសម្តេចព្រះរាជមទ្រីថា «ហៃមទ្រី ដ៏មានលក្ខណាប្រសើរអើយ នាងសព្វថ្ងៃធ្លាប់លាបនូវសុគន្ធពិដោរ លំអិតខ្លឹមច័ន្ទន៍ក្រចេះម្សៅ ធ្លាប់ស្លៀកសំពត់ខោមពស្ត្រ កាសិកពស្ត្រ ម្តេចឡើយ នាងនឹងទៅទ្រង់នីទៅនូវញើសក្អែល ហើយស្លៀកនីទៅនូវសំពត់

Websites: WatKhemaraRatanaram.org or WatKhmers.org

សំបកឈើ គិតដ៏អន្ទកក្រងមួយអន្លើ នូវស្បូវភ្លាំង នឹងជាទុក្ខស្រអ័ញស្រអុក ព្រោះ សំពត់នៅនាព្រៃនោះដូចម្តេចបានឡើយ ។

តមព្ពិ រាជបុត្តី មទ្ទី សព្វង្គសោភនា
ជាហន្តំ សុខមិច្ឆេយ្យំ យំ មេ វេស្សន្តរំ វិនាតិ ។

ក្សិណនោះកូវ សម្តេចព្រះរាជមទ្រី ដ៏ជាក្សត្រិយ៍ប្រសើរនាងក្រាបទូលស្នងព្រះរាជឱង្ការវិញថា «បពិត្រក្សត្រថ្លៃប្រសើរអើយ វីស្រុកជេតុត្តរនគរនេះ គួរគប្បីអញខ្ញុំត្រេកអរ ចង់នៅនាឋានសុខនេះ តែអញខ្ញុំពុំប្រាថ្នាចង់នៅដល់តិចឡើយ បើព្រាត់ប្រាសព្រះបាទស្រីវេស្សន្តរ ឲ្យទ្រង់ទៅនៅលំបាកតែមួយព្រះអង្គឯង ឯព្រៃនោះ ពុំសមគួរឡើយ ។

តមព្ពិ មហារាជា សិវីនំ រដ្ឋវឌ្ឍនោ
ឥជ្ឈ មទ្ទី និសាមេហិ វនេ យេ ហោន្តិ ទុស្សហា ។
ពហូ កីដា បដង្គា ច មកសា មធុមក្ខិកា
តេបិ តំ តត្ថ ហឹសេយ្យុំ តន្តេ ទុក្ខតរំ សិយា ។
អបរេ បស្ស សន្តាសេ នទីនូបនិសេវិតេ

Websites: WatKhemaraRatanaram.org or WatKhmers.org

សប្បា អជគរា នាម | អវិសា តេ មហព្វលា ។
តេ មនុស្សំ មិគំ វាបិ | អបិចាសន្នមាគតំ
បរិក្ខិបិត្វា ភោគេហិ | វសមានេន្តិ អត្តនោ ។
អញ្ញេបិ កណ្ហា ជដិនោ | អច្ឆា នាម អឃម្មិគា
ន តេហិ បុរិសោ ទិដ្ឋោ | រុក្ខមារុយ្ហ មុច្ចតិ ។
សង្ឃដ្ដយន្តា សិង្គានិ | តិក្ខគ្គានិ បហារិនោ
មហិសា វិចរន្តេត្ថ | នទី សោតុម្ពរំ បតិ ។
ទិស្វា មិគានំ យូថានំ | គវំ សញ្ចរិតំ វនេ
ធេនុវ វច្ឆគិទ្ធាវ | កថំ មទ្ទិ ករិស្សសិ ។
ទិស្វា សម្បតិតេ ឃោរេ | ទុម្មគ្គេសុ បល្វង្គមេ
អខេត្តញ្ញាយ តេ មទ្ទិ | ភវិស្ស តេ មហព្ភយំ ។
យា ត្វំ សិវាយ សុត្វាន | មុហុំ ឧត្តសតេ បុរេ
ស្វា ត្វំ វង្កំ អនុប្បត្តា | កថំ មទ្ទិ ករិស្សសិ ។
ឋិតេ មជ្ឈន្តិកេ កាលេ | សន្និសិន្នេសុ បក្ខិសុ
សុណាតេវ ព្រហារញ្ញំ | តត្ថ កឹ គន្តុមិច្ឆសិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្ធដ៏ក្បិណនោះកូវ រីព្រះបាទស្រីសញ្ជ័យ ដ៏ជាស្តេចធំប្រសើរ មានព្រះបន្ទូលថា «ហៃនាងមទ្រីអើយ អាពុកនឹងស្រដីប្រាប់មេ មេអើយ រីកំណើតព្រៃព្រះហេមពាន្តនោះកម្រក្តាត់ ដ៏ពាសពេញនីទៅនូវសត្វម្រឹគសឹងតែសាហាវច្រើន ទោះតាឱ ទោះស្រាំង ឃ្មុំក្តីមេអើយ រីសត្វអស់នោះមកចោមរោមនៅជាច្រើន មានព្ធដ៏ព្រៃនោះហោង ។

មួយសោត រីសត្វឯទៀតក៏មានជាច្រើន មុខគួរឲ្យខ្លាចពន់ពេក ។ រីពស់មួយនោះ លោកហៅថាពស់ថ្លាន់ ដ៏មានកម្លាំងច្រើនក្តាត់ វាបានយល់មនុស្សក្តី សត្វអ្វីៗ នីមួយក្តី ដែលចូលមកអាស្រ័យនាទឹកស្ទឹងមុចលិន្ទនទី កាលណាបើពស់នោះវាយល់ហើយវាដេញដោយនូវកម្លាំងរបស់វា ទោះនឹងចុងឈើខ្ពស់អម្បាលម៉ានក្តីក៏មិនរួចនឹងវាឡើយ កាលបើវាដេញទាន់ហើយ វាព័ន្ធព័ទ្ធរឹតនឹងភ្នែនកន្ទុយវានោះ ល្អិតឆ្អឹងអស់ហើយវាលេបដោយនូវអំណាចវាហោង ។

មួយសោត មេអើយ រីសត្វមួយនោះលោកហៅថាខ្លាឃ្មុំដ៏មានរោមនោះខ្មៅគគ្រោត កាលណា បើវាយល់មនុស្សឯណាមួយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ដើរទៅហើយ ទោះបើវត់ឡើងដើមឈើខ្ពស់អម្បាលម៉ានក្ដី ក៏មិនរួចនឹងវាឡើយ បើវាចាប់បានហើយវាជញ្ជក់យកឈាមស្ងួតក្រៀមទៅ ថាបើមេនឹងទៅនោះ ពិតជាលំបាកពេកហោង ។ មួយសោត រីក្របីព្រៃដ៏មានស្នែងនោះវែងស្រួចក្ដាត់ កាលណាបើវាយល់មនុស្សហើយ វារត់ដេញវ៉ៃធមុតមែនក្ដាត់ ។ ទោះបីពេលព្រឹកក្ដី ល្ងាចក្ដី វាតែងបណ្ដើរកូនទៅត្រាំទឹក ស្ទឹងបឹងសាគរនទីនោះ នៅត្រង់នាផ្លូវនឹងដើរទៅកាន់ព្រៃព្រះហេមពាន្ត ដ៏ជាឋានលំនៅលំបាកនោះហោង ។

មួយសោត មទ្រីអើយ រីទន្សោង គោព្រៃ កាលបើថ្ងៃរសៀលទន់ទាប វាជល់គ្នាលេងដោយផ្លូវ វាស្រែកពោទ៏ប្រដេញគ្នាទៅមក មុខគួរឲ្យខ្លាចពេក ។ មួយសោត រីផ្លូវហ្វូងស្វាផងទាំងឡាយ វាយល់មនុស្សនៅនាព្រៃស្ងាត់ដូច្នេះ វានឹងមកចោមរោមសំបើមមុខគួរឱ្យខ្លាច គួរស្ញើមពេក ។ ហៃនាងមទ្រីអើយ នាព្រលប់នោះសោត រីឯសត្វបក្សីគឺ មៀម ទីទុយ ខ្លែងស្រាក ចចក លលកខ្មោច ទោច ឪឡុ ភ្ញាំង ស្វាំង គូក វានឹងហើរមកទំស្រែកយំនៅនាដើមឈើ ក្បែរខាងលំនៅនោះ មុខគួរស្ញើមពេកហោង ។ ហៃនាងមទ្រីជាក្សត្រិយ៍

ប្រសើរអើយ នាភ័យទាំងអម្បាលនោះ ហេតុតែនាងមិនដែលឮ មិនដែលឃើញមិញ ថាបើនាងបានឮបានឃើញហើយ ក៏នាងនឹង ស្បើមព្រឺប្រុងសម្រុង សរីរៈអស់ទាំងខ្លួន នាងនឹងយំបម្រះអន្ទះ អន្ទែង គ្រញែងឯងលំបាកពន់ពេក ។ ម្រាងឡើយនាងទៅ និង នៅនាភ្នំគិរីវង្កតបពិតនោះបាន ចូរនាងនៅអាយជាមួយនឹងមេក្មេក បាក្មេកនេះហោង ។

តមព្វិ រាជបុត្តី　　មទ្ទី សព្វង្គសោភណា
យានិ ឯតានិ អក្ខាសិ　　វនេ បដិភយានិ មេ
សព្វានិ អភិសម្ភោសំ　　គច្ឆញ្ញេវ រថេសភ ។
កាសំ កុសំ ចោតកិលំ　　ឧសិរំ មុញ្ជបព្វជំ
ឧរសា បនុទហិស្សាមិ　　នាស្ស ហិស្សាមិ ទុន្នយា
ពហូហិ វត្តចរិយាហិ　　កុមារី វិន្ទតេ បតឹ
ឧទរស្សុបរោធេន　　គោហនុវេដ្ឋនេន ច
អគ្គិស្ស ចារិចរិយាយ　　ឧទកុម្មុជ្ជនេន ច
វេធព្យំ កដុកំ លោកេ　　គច្ឆញ្ញេវ រថេសភ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អបិស្សា ហោតិ អប្បត្តោ ឧច្ឆិដ្ឋំ បរិភុញ្ជិតុំ
យោ នំ ហត្ថេ គហេត្វាន អកាមំ បរិកឌ្ឍតិ
វេធព្យំ កដុកំ លោកេ គច្ឆញ្ញោវ រថេសភ ។
កេសគ្គហណមុក្ខេបា ភូម្យា ច បរិសុម្ភនា
ទត្វា ច នោ បក្កមតិ ពហុំ ទុក្ខំ អនប្បកំ
វេធព្យំ កដុកំ លោកេ គច្ឆញ្ញោវ រថេសក ។
សុក្កច្ឆវី វេធវេរា ទត្វា សុភគ្គមានិនោ
អកាមំ បរិកឌ្ឍន្តិ ឧលូកញ្ញេវ វាយសា
វេធព្យំ កដុកំ លោកេ គច្ឆញ្ញោវ រថេសភ ។
អបិ ញាតិកុលេ ផីតេ កំសប្បជ្ជោតនេ វសំ
នេវាតិវាក្យំ ន លភេ ភាតូហិ សខីហិ ច
វេធព្យំ កដុកំ លោកេ គច្ឆញ្ញោវ រថេសភ ។
នគ្គា នទី អនូទកា នគ្គំ រដ្ឋំ អរាជិកំ
ឥត្ថីបិ វិធវា នគ្គា យស្សាបិ ទស ភាតរោ

Websites: WatKhemaraRatanaram.org or WatKhmers.org

វេធព្យំ កដុកំ លោកេ　　គច្ឆញ្ញេវ រថេសភ ។
ធជោ រថស្ស បញ្ញាណំ　　ធូមោ បញ្ញាណមគ្គិនោ
រាជា រដ្ឋស្ស បញ្ញាណំ　　ភត្តា បញ្ញាណមិត្ថិយា
វេធព្យំ កដុកំ លោកេ　　គច្ឆញ្ញេវ រថេសភ ។
យា ទលិទ្ទី ទលិទ្ទស្ស　　អឌ្ឍា អឌ្ឍស្ស កិត្តិមា
តំ វេ ទេវា បសំសន្តិ　　ទុក្ករំ ហិ ករោតិ សា
សាមិកំ អនុពន្ធិស្សំ　　សទា កាសាយវាសិនី ។
បថព្យាបិ អភិជ្ជន្ត្យា　　វេធព្យំ កដុកិត្ថិយា
អបិ សាគរបរិយន្តំ　　ពហុវិត្តធរំ មហឹ
នានារតនបរិបូរំ　　និច្ឆេ វេស្សន្តរំ វិនា ។
កថន្នុ តាសំ ហទយំ　　សុខរា វត ឥត្ថិយោ
យា សាមិកេ ទុក្ខិតម្ហិ　　សុខមិច្ឆន្តិ អត្តនោ ។
និក្ខមន្តេ មហារាជេ　　សិវីនំ រដ្ឋវឌ្ឍនេ
តមហំ អនុពន្ធិស្សំ　　សព្វកាមទទោ ហិ មេតិ ។

ក្សិណនោះកូវ សម្តេចព្រះរាជមទ្រី រាជបុត្រីស្រីវ័ត្ន ដ៏ប្រកប

Websites: WatKhemaraRatanaram.org or WatKhmers.org

នូវលក្ខណាប្រសើរព្រះនាងលើក ព្រះហស្តប្រណម្យក្រាបទូលថា «បពិត្រព្រះមហាក្សត្រធិរាជប្រសើរអើយ ព្រះអង្គតែងទ្រង់ចំរើនអ្នកស្រីពិរាស្រ្ត ទ្រង់មានព្រះបន្ទូលនោះពីរោះក្លាត់ ។ បពិត្រអម្ចាស់អើយ វីត្រង់ទុក្ខភ័យនោះ អញខ្ញុំនឹងអធ្យោគទៅនឹងប្តីអញខ្ញុំ ៗ នឹងចងក្បិនឲ្យខ្ជាប់ ហើយអញខ្ញុំនឹងដើរទៅមុនព្រះបាទវេស្សន្តរ នឹងពារបញ្ជាន់បែនកិនទៅ ទោះទាំងព្រៃបបុស ត្រែង អំពៅព្រៃក្តី ស្មៅសសិត ស្បូវភ្លាំង ស្បូវណ្តាស ស្មៅដំណេកទន្សាយក្តី ស្មៅយាប្លងក្តី ក៏អញខ្ញុំនឹងទន្ទ្រានច្រានពានទៅមុខ មិនឲ្យដិតត្រូវព្រះបាទា ព្រះបាទស្រីវេស្សន្តរ ព្រះស្វាមីអញខ្ញុំជាព្រះរាជបុត្រព្រះអង្គនេះឡើយ ។ បពិត្រអម្ចាស់អើយ អ្វីកម្រនៅនាព្រៃនោះ ក៏អញខ្ញុំមិនឲ្យព្រះអង្គព្រួយលំបាកឡើយ វីក្តីលំបាកមាននៅត្រង់ណា ក៏អញខ្ញុំធានាត្រង់ណោះមិនឲ្យព្រះរាជបុត្រអម្ចាស់លំបាកតែមួយព្រះអង្គឯងឡើយ» ។

បពិត្រព្រះមហាក្រត្សថ្លៃប្រសើរអើយ អញខ្ញុំអម្ចាស់នេះមានឧបមា បីដូចក្រមុំផងទាំងឡាយ នៅសព្វថ្ងៃនេះ សង្វាតចង់បានប្តីឲ្យជាទីគាប់ចិត្តនោះ អញខ្ញុំអម្ចាស់ដោះឡើងអំពីព្រឹក ហើយបបួលគ្នាទៅកាច់ស្ទន់មកទន់ ហើយអង្គុយនៅមាត់ទឹក ហើយស្រដី

អំភ្លាងគាងទៅគាងមក ដូចកលស្នែងគោ ហើយចុះងូតទឹកជម្រះខ្លួន រួចទៅផ្ទះយកប្រេងម្សៅលាប ហើយហូបបាយពុំឲ្យឆ្អែតពេក ខ្លាចក្រែងវាធាត់រលកន្ទ្រលមិនស្រឡាញ់ ។ អម្ចាស់អើយ ធ្វើទាំងអម្បាលណោះនៃ ទើបមានប្ដីជាទីគាប់ចិត្ត ក៏ឥឡូវនេះអញខ្ញុំបានប្ដីជាទីគាប់ចិត្តដូចប្រាថ្នាហើយ ម្ដេចឡើយក៏អញខ្ញុំនឹងនៅជាមេម៉ាយ ។ អម្ចាស់អើយ ត្រង់ស្រីមេម៉ាយនោះ ប្រុសទាំងឡាយគេមើលងាយនាលោកិយនេះពេកក្ដាត់ ។ បទអ្វីអញខ្ញុំពោលថាដូច្នោះ អម្ចាស់អើយ រីស្រីមេម៉ាយផងទាំងឡាយសព្វថ្ងៃនេះ ទោះបីដើរទៅទីឯណានីមួយក្ដី ទោះអង្គុយនៅក្ដី ទោះជូនជាហូបបាយក្ដី ធ្វើការក្ដី ក៏ប្រុសឯណាមួយបានយល់ ជាទីគាប់ចិត្តវាហើយ វានឹងមើលងាយតាមចំណង់ចិត្តវា ហើយវានឹងមកចាប់ដៃទង់ទៅ បើពុំទៅដោយចិត្តវាហើយ ក៏វានឹងចាប់សក់គក់ត្បូកភើចទង់ទៅឲ្យតែបាន មានឧបមាបីដូចអ្វី ថាឧបមាបីដូចកូនក្អែកចឹកកូនមៀម ទង់ចេញអំពីសំបុកនោះឯង ។ បពិត្រអម្ចាស់អើយ ហេតុនេះអញខ្ញុំមិននៅជាស្រីមេម៉ាយនេះឡើយ អញខ្ញុំនឹងទៅតាម ព្រះបាទស្រីវេស្សន្តរជាប្ដីអញខ្ញុំហោង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បពិត្រក្សត្រថ្លៃប្រសើរអើយ រីស្រីមេម៉ាយនេះ ទោះបីមានរូបឆោមអម្បាលម៉ានក្តី ទោះលាបប្រេងម្សៅក្រចេះចូងច័ន្ទន៍ មានគន្ធពិដោរក្តី ទោះមានគ្រឿងមាសគ្រឿងប្រាក់ក្តី ទោះនៅក្នុងត្រកូលស្តេចក្តី តែគេយល់ថាជាឥតប្តីហើយ គេនឹងថាស្រីមេម៉ាយដដែលហោង ។ បពិត្រអម្ចាស់អើយ ហេតុតែដំណើរដូច្នេះឯង ក៏អញខ្ញុំនឹងសង្វាតទៅតាមព្រះវេស្សន្តរ ជាម្ចាស់លើត្បូងនៃអញខ្ញុំ ។

បពិត្រអម្ចាស់អើយ នទី រីស្ទឹងឯណា អនូទកា គឺឥតទឹកឡើយ នគ្គា ហៅថាស្ទឹងទទេ ។ រដ្ឋំ រីនគរមណ្ឌលរាស្ត្ររដ្ឋផងទាំងឡាយ អរាជិកំ ថាបើឥតស្តេចគង់ហើយ នគ្គំ ហៅថាស្រុកទទេ ពុំហៅនគរប្រសើរឡើយ ។ អបិ មួយនីសោត យា ឥត្ថី រីស្រីឯណា វិធវា បើឥតនឹងប្តី ហៅថាស្រីមេម៉ាយហោង ។ រថេសភ បពិត្រអម្ចាស់អើយ វេធព្យំ រីភាពជាស្រីមេម៉ាយនោះ កដុកំ មុខគួរឱ្យជាទុក្ខសោតពេក លោកេ ឮដ៏លោកនេះ ។ តេន ហេតុនោះហោង អហំ រីអញខ្ញុំ គច្ឆញ្ញេវ នឹងទៅតាមព្រះបាទស្រីវេស្សន្តរដ៏ជាព្រះស្វាមីនៃអញខ្ញុំជាប្រាកដហោង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បពិត្រមហារាជ ដ៏ក្សត្រធំឧត្តមប្រសើរអើយ រីរាជរថដ៏ប្រដាប់នីទៅនូវទង់ចង្រ្កង់នាគ កណ្តឹងនោះនៃ ទើបប្រាកដហៅថារាជរថ ។ រីភ្លើងសោត បើមានផ្សែងឡើងហើយនោះនៃ ទើបប្រាកដហៅថាភ្លើង, ដូចស្រុកនគរសោត ថាបើមានស្តេចសោយរាជ្យស្តល់នៅនោះនៃ ទើបហៅថាជាស្រុកប្រសើរ នគរប្រសើរ ។ រីឯស្រីសព្វថ្ងៃនេះ ថាបើមានប្តីនោះនៃ ទើបហៅថាស្រីប្រសើរ ថាបើឥតប្តីហើយគេក៏ហៅជាស្រីមេម៉ាយហោង ។ ហេតុនេះ បពិត្រអម្ចាស់អើយ ធម្មតាស្រីមេម៉ាយនេះ ជាចំណាយមាត់អ្នកផងក្តាត់ហោង ។ រីស្រីព្វដ៏លោកិយសព្វថ្ងៃនេះ បើប្តីខ្សត់ហើយ ប្រពន្ធនោះក៏ខ្សត់ផង ។ បើប្តីមានយសសក្តិហើយ ស្រីនោះក៏នៅនឹងយសសក្តិសម្បត្តិប្តីនោះ ។ បពិត្រអម្ចាស់អើយ បើស្រីឯណាឧស្សាហ៍អធ្យោគបំរើប្តី នាលោកិយនេះក៏ប្រសើរឥតហ្មង លុះដល់អនាគតកាលទៅឯភ្នែកសោត តែងនឹងបានសម្បត្តិសួគ៌ រួចដល់និព្វាននោះទៀងប្រាកដហោង ។ បពិត្រក្សត្រថ្លៃប្រសើរអើយ ហេតុនេះហោង អញខ្ញុំនឹងទៅស្លៀកសំពត់សំបកឈើ គិតដ៏អ្នកក្រងនីទៅនូវស្បូវភ្លាំង ហើយនឹងស្ពាយឆៀង

Websites: WatKhemaraRatanaram.org or WatKhmers.org

នូវស្បែកខ្លា ឥតក្រយាសោយក្តី ក៏អញខ្ញុំសង្វាតទៅតាមព្រះបាទវេស្សន្តរ ជាព្រះរាជស្វាមីអញខ្ញុំ ។ អម្ចាស់អើយ អញខ្ញុំបានព្រះបាទស្រីវេស្សន្តរជាព្រះស្វាមី ឰដ៏លោកិយនេះ មិនឲ្យអ្នកឯណាមួយមកដៀលថា ជាស្រីមេម៉ាយបានឡើយ ។ ហេតុនេះ អញខ្ញុំនឹងទៅតាមព្រះបាទស្រីវេស្សន្តរ ជាព្រះរាជស្វាមីសម្លាញ់នៃអញខ្ញុំហោង ។

បពិត្រអម្ចាស់អើយ វីសម្បត្តិឯណាមានឰដ៏ជេតុត្តរនគរពេញនីទៅនូវរ័ត្នទាំង ៧ ក្តី ទោះទ្រព្យឯណាផ្សេងក្តី ទោះអញខ្ញុំនឹងស្រឡាញ់អាល័យសម្បត្តិនោះ ឥតអង្គីមានឡើយ បើព្រាត់ប្រាសព្រះបាទស្រីវេស្សន្តរចេញទៅនោះ វាក្តៅផ្សាជាទុក្ខតែម្នាក់ឯង ។ បពិត្រអម្ចាស់អើយ វីព្រះបាទស្រីវេស្សន្តរ អ្នកចេញទៅពីស្រុកនេះ នាកាលថ្ងៃឯណាមិញ ក៏អញខ្ញុំនឹងចងក្បិនឲ្យខ្ជាប់ ហើយអញខ្ញុំនឹងពកូនទាំង ២ ទៅតាមព្រះបាទស្រីវេស្សន្តរជាព្រះស្វាមីអញខ្ញុំ នាថ្ងៃនោះហោង ។

តមព្រវិ មហារាជា មទ្ទី សព្វង្គសោភនំ
ឥមេ តេ ទហរា បុត្តា ជាលី កណ្ហាជិនា ចុភោ
និក្ខិប្ប លក្ខណេ គច្ឆ មយ្ហេ ចោសិយាមសេតិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ហៃសប្បុរសផងទាំងឡាយអើយ រីព្រះបាទស្រីសញ្ជ័យ ដ៏ជាស្ដេចធំប្រសើរនោះ ទ្រង់ស្រដីលួងលោមសម្ដេចព្រះរាជមទ្រី ក៏ព្រះនាងពុំព្រមនៅឡើយ ទើបស្ដេចមានព្រះបន្ទូលវិញទៀតថា «ហៃនាងមទ្រីអើយ បើនាងពុំយកពាក្យឪពុកហើយ នាងនឹងទៅតាមបាវេស្សន្តរ ក៏តាមតែចិត្តនាងចុះ រីកូនទាំង ២ គឺចៅជាលី និងមេក្រស្នា ចូរនាងទុកនៅអាយ យើងជាម្ដាយឪពុកនឹងចិញ្ចឹមរក្សាហោង» ។

តមព្រវិ រាជបុត្តី មទ្ទី សព្វង្គសោភនា
បិយា មេ បុត្តកា ទេវ ជាលី កណ្ហាជិនា ចុភោ
ត្យម្ហំ តត្ថ រមិស្សន្តិ អរញ្ញេ ជីវិសោកិនន្តិ ។

រីសម្ដេចព្រះរាជមទ្រី ដ៏ជាព្រះរាជបុត្រីស្រីវ័ត្ន ដ៏មានលក្ខណាប្រសើរនោះ ព្រះនាងស្ដាប់ព្រះបន្ទូលហើយ ក៏ក្រាបទូលថា បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ រីកូនទាំង ២ ចៅជាលី និងមេក្រស្នានេះមិញ មិនមែនជាកូនសំអប់ អញខ្ញុំមិនព្រមឲ្យប្រាសចេញអំពីទ្រូងអញខ្ញុំអម្ចាស់ឡើយ ។ ហេតុនេះ អញខ្ញុំចិញ្ចឹមជីវិតរស់នៅ ដោយប្រការដូចម្ដេចមិញ នាអញខ្ញុំនឹងរកចិញ្ចឹមកូនអញខ្ញុំទាំង

Websites: WatKhemaraRatanaram.org or WatKhmers.org

២ ឲ្យមានជីវិតរស់នៅ ដោយប្រការដូច្នោះហោង›› ។

តមព្រវិ មហាភជា សិរីធំ រជ្ជវឡ្ហោ
សាលីនមោទនំ ភុត្វា សុចិមំសូបសេចនំ
រុក្ខផលានិ ភុញ្ជន្តា កថំ កាហន្តិ ធារកា ។
ភុត្វា សតបលេ កំសេ សោវណ្ណេ សតរាជិកេ
រុក្ខបត្តេសុ ភុញ្ជន្តា កថំ កាហន្តិ ធារកា ។
កាសិយានិ ច ធារេត្វា ខោមកោទុម្ពរានិ ច
កុសចីរានិ ធារេន្តា កថំ កាហន្តិ ធារកា ។
វយ្ហា ហិ បរិយាយិត្វា សិវិកាយ រថេន ច
បត្តិកា បរិធាវន្តា កថំ កាហន្តិ ធារកា ។
កូដាគារេ សយិត្វាន និវាតេ ផុស្សិតគ្គឡេ
សយន្តា រុក្ខមូលស្មឹ កថំ កាហន្តិ ធារកា ។
កូដាគារេ សយិត្វាន និវាតេ ផុស្សិតគ្គឡេ
សយន្តា រុក្ខមូលស្មឹ កថំ កាហន្តិ ធារកា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បល្លង្កេសុ សយិត្វាន គោនកេ ចិត្រសន្ថតេ
សយន្តា តិណសន្ថារេ កថំ កាហន្តិ ទារកា ។
កន្ទកេន វិលិម្បិត្វា អគ្គលុចន្ទនេន ច
រជោជល្លានិ ធារេន្តា កថំ កាហន្តិ ទារកា ។
ចាមរីមោរហត្ថេហិ វីជិតង្គា សុខេ ឋិតា
ផុដ្ឋា ឌំសេហិ មកសេហិ កថំ កាហន្តិ ទារកា ។

កាលនោះ ព្រះបាទស្រីសញ្ជ័យ មានព្រះបន្ទូលវិញទៀតថា «ហៃនាងមទ្រីអើយ រីក្មេងទាំង ២ នេះ ធ្លាប់បរិភោគនូវភោជ្ជសាលីស ល្អបរិសុទ្ធ ដ៏ប្រដាប់នីទៅនូវត្រីសាច់ ញាំភ្លាសាកប់ផង តម្កល់ទុក លើភាជន៍មាស គិតដ៏អ្នកគួរកាច់រចនានូវក្បាច់ ១០០ ជាន់ ទើបក្មេង ទាំងពីរនេះបរិភោគបាន ឥឡូវនេះនឹងនាំទៅឲ្យបរិភោគ នូវផ្លែឈើ ដាក់លើដីនាព្រៃនោះ ធ្វើម្តេចក្មេងទាំង ២ នឹងបរិភោគបាន ។ មួយ សោត ក្មេងទាំង ២ ធ្លាប់ទ្រទ្រង់នូវសំពត់ខោមពស្ត្រ កោទុម្ពរពស្ត្រ ធ្លាប់ជិះគ្រឿងស្នែង រមែងជិះរាជរថ ពាជី ដំរី ប្រសើរ ឥឡូវនេះមេនឹង នាំក្មេងទាំង ២ ទៅតែជើងទទេ ហើយឲ្យស្លៀកសំពត់ សំបកឈើ

គិតដ៏អ្នកច្រៀកក្រងនីទៅនូវស្បូវភ្លាំង ហើយស្លាយឆៀងស្បែកខ្លាទាំង ក្រចក បរិភោគនូវផ្លែឈើ ស្លឹកឈើ នៅនាព្រៃនោះដូចម្ដេចបាន ។ មួយសោតមទ្រីអើយ រីក្មេងទាំង ២ នេះ ធ្លាប់ដេកក្នុងព្រះរាជមន្ទីរ ដ៏ប្រដាប់នីទៅនូវគ្រែទែនកែវ ដ៏ត្រកាលពាសពេញ នីទៅនូវចៀម ចំព្រៃព្រំ រនាំងរាំងននពុំលេចខ្យល់ ទើបក្មេងទាំង ២ ដេកលក់ ស្រណុកសុខសប្បាយ ។ មួយសោត រីក្មេងទាំង ២ នេះ ធ្លាប់តែង រមែងលាបស្រឡាបនីទៅនូវប្រេងម្សៅ ក្រចេះលំអិតខ្លឹមច័ន្ទន៍ក្រស្នាភ្លាំ ពាក់ ធ្លាប់ឲ្យបក់នីទៅនូវផ្លិតចាមរព្រុយក្បោក ទើបដេកលក់ស្រណុក សុខសប្បាយ ។ មទ្រីអើយ ឥឡូវនេះនាងនឹងនាំក្មេងទាំង ២ នេះទៅ ប្រឡាក់នូវផង់ធូលី ដីខ្សាច់ ញើសក្អែល ហើយឲ្យដេកលើកម្រាល ស្លឹកឈើ លើដីនៅនាព្រៃនោះ ត្រូវខ្យល់ភ្លៀងផង ធ្វើម្ដេចឡើយ នឹង ដេកនៅស្រណុក សមក្មេងនឹងយំជាទុក្ខក្រៃពេកពួដ៏ព្រៃនោះហោង។

ឯវំ តេសំ សល្លបន្តានញ្ញេវ រត្តិ វិភាយិ សុរិយោ ឧគ្គច្ឆតិ ។ រីក្សត្រទាំងបីព្រះអង្គ ស្រដីផងគ្នានូវប្រការអម្បាលនោះ ហើយក្ធូវ ព្រះអាទិត្យក៏រះឡើង ។ ក្សិណនោះ អាមាត្យនាយរាជរថ

Websites: WatKhemaraRatanaram.org or WatKhmers.org

ប្រដាប់ទឹមនូវសេះអាជានេយ្យទាំង ៤ បរទៅដាក់នៅមុខទ្វារព្រះរាជវាំងព្រះមហាសត្វ ។ ក្សិណនោះក្ដី សម្ដេចព្រះរាជមទ្រីក្រាបថ្វាយបង្គំលាមេក្មេកបាក្មេកហើយ ទ្រង់ស្រដីផ្ដាំនូវអស់ស្រីព្រះស្នំទាំងអម្បាលនោះហើយ ទើបព្រះនាងពយកព្រះរាជបុត្រទាំង ២ ដើម្បីឡើងទៅគង់លើព្រះរាជរថនោះ មុនព្រះមហាក្សត្រជាព្រះស្វាមីហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ វីអាថិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថៃងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះបរមសាស្ដាទ្រង់មានព្រះបន្ទូលសូត្រសានូវគាថាដូច្នេះ ៖

តមព្រវី រាជបុត្តី   មទ្ទី សព្វង្គសោភនា
មា ទេវ បរិទេវេសិ   មា ច ត្វំ វិមនោ អហុ
យថា មយំ គមិស្សាម   តថា ហេស្សន្តិ ញាតកោ ។
ឥទំ វត្វាន បក្កាមិ   មទ្ទី សព្វង្គសោភនា
សិវិមគ្គេន អន្វេសិ   បុត្តេ អាទាយ លក្ខណាតិ។

ភិក្ខុអើយ ឮដំកាលនោះ សម្ដេចព្រះរាជមទ្រីជាព្រះរាជបុត្រីស្រីវត្តប្រសើរ ព្រះនាងក្រាបទូលព្រះបាទស្រីសញ្ជ័យ ជាបាក្មេកដូច្នេះ

Websites: WatKhemaraRatanaram.org or WatKhmers.org

បពិត្រក្សត្រថ្លៃប្រសើរអើយ កុំអម្ចាស់គិតអាណិតខ្សឹកខ្សួលរំជួល ក្នុងព្រះរាហឫទ័យ នឹងព្រះចៅអម្ចាស់ទាំង ២ នេះឡើយ, រីយើងខ្ញុំទាំង ២ នេះ នឹងទៅចិញ្ចឹមជីវិតរស់នៅដូចម្ដេចមិញ ក៏ចៅអម្ចាស់ទាំង ២ រស់នៅដូច្នោះហោង ។

តតោ វេស្សន្តរោ រាជា ធាតំ ឧត្វាន ខត្តិយោ
បិតុ មាតុញ្ច វន្ទិត្វា កត្វា ច នំ បទក្ខិណំ
ចតុវាហឹ រថំ យុត្តំ សីឃមារុយ្ហ សន្ទនំ
អាទាយ បុត្តទារញ្ច វង្កំ បាយាសិ បព្វតន្តិ ។

ព្វដ៏ក្សិណនោះ ព្រះបាទស្រីវេស្សន្តរ ក្រាបថ្វាយបង្គំលាព្រះវររាជមាតាបិតាហើយ ស្ដេចដោះឡើងប្រទក្សិណ ៣ ជុំ ហើយឡើងទៅគង់លើរាជរថ ទឹមនីទៅនូវសេះអាជានេយ្យទាំង ៤ បរនាំព្រះរាជបុត្រ ព្រះរាជទេពី ទៅដោយនូវផ្លូវទៅកាន់ភ្នំវង្កតបព៌ត តាមពាក្យអ្នកស្រីពិរាស្ត្រគេបណ្ដេញនោះហោង ។

តតោ វេស្សន្តរោ រាជា យេនាសិ ពហុកោ ជនោ
អាមន្ត ខោ តំ គន្ត្វាន អរោគា ហោន្តុ ញាតយោតិ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ឰដ៏ក្សិណនោះ ព្រះបាទស្រីវេស្សន្តរ ទ្រង់ទតយល់ទីណា មានមហាជនជំនុំគ្នាច្រើន ស្ដេចក៏បររាជរថទៅកាន់ទីនោះ ដើម្បីទ្រង់មានព្រះរាជបន្ទូលលាថា «ម្នាលញាតិទាំងឡាយអើយ សូមឲ្យអ្នកទាំងឡាយ កុំបីមានរោគាព្យាធិបៀតបៀនយាយី, សូមឲ្យបានសេចក្ដីសុខសប្បាយរាល់ៗ គ្នាទៅហោង» ។

គច្ឆន្តេ ពោធិសត្តស្ស មាតា បុត្តោ មេ ធានចិត្តកោធាធំ ទេត្វតិ អាភរណេហិ សទ្ធឹ សត្តរតនប្ងាធិ សកជាធិ ឧភោសុ បស្សេសុ បេសេសិ ។ កាលបើព្រះពោធិសត្វ ទ្រង់បររាជរថឆ្ពោះទៅរកព្រះនាងសុបារសុប្បតី ដ៏ជាព្រះមាតាព្រះពោធិសត្វនោះ ព្រះនាងមានព្រះរាជបន្ទូលនឹងអាមាត្យថា «ម្នាលអាមាត្យអើយ រីកូនអញនោះ ជាអ្នកស្រឡាញ់ទាននោះច្រើន ចូរអ្នកយកផ្ទិមអម្ពរស្បៃគ្រឿងប្រដាប់នូវរ័ត្នទាំង ៧ ប្រការ ទៅបំពេញកំឡុងក្នុងរាជរថ ឱ្យពាសពេញកំពុងទាំងសងខាងរថកុំបីឲ្យខ្វះឡើយ» ។

រីព្រះបាទស្រីវេស្សន្តរ ដ៏ជាក្សត្រប្រសើរនោះ បររាជរថទៅយល់អស់មហាជនផងទាំឡាយ ជំនុំគ្នាត្រង់ឋានឯណាច្រើនមិញ ក៏

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះអង្គបររាជរថតម្រង់ទៅឋាននោះហោង ។ ព្រះអង្គព្រះរាជទានគ្រឿងប្រដាប់ ទៅជាទាន ដល់មហាជនផងទាំងឡាយ ហើយព្រះអង្គឲ្យដំបូន្មានថា «ហៃញាតិផងទាំងឡាយអើយ អ្នកនៅឯក្រោយចូរឲ្យស្រណុកសុខសប្បាយ កុំបីមានជម្ងឺតំកាត់ឡើយ ។ ហៃអស់ញាតិផងទាំងឡាយអើយ ចូរអ្នកទាំងឡាយ កាន់សីលឲ្យទានកុំបីធ្វេសប្រហែសឡើយ» ។ ព្រះពោធិសត្វមានព្រះបន្ទូលដូច្នេះហើយទើបស្តេចបររាជរថចេញពីព្រះនគរទៅ ។ ព្រះពោធិសត្វមហាបុរសវ័ត្ថដ៏វិសេសប្រសើរ ស្តេចឲ្យទានរៀងទៅដោយនូវផ្លូវនោះឯងជាគំរប់ ១៨ ដង ដរាបលុះអស់ ឥតអ្វីជាសំណល់ឡើយ ។ ក្សិណនោះ ព្រះពោធិសត្វ ស្តេចបង្វិលរាជរថ ចេញពីព្រះនគរ ហើយបែរព្រះនេត្រទតមើលមក កាន់ព្រះនគរវិញ ។ ក្សិណនោះ មហាប្រឹថពីឯង ក៏សញ្ជែកប្រេះបែកជា ៧ ភាគ ទំហំប៉ុនកង់រាជរថ មានត្រង់នាឋានព្រះមហាក្សត្រស្តេចបង្វិលរាជរថនោះឯង ។

តេន វុត្តំ ហេតុនោះហោង ព្រះអង្គបានត្រាស់ប្រាជ្ញាសព្វេញ្ញុតាញាណ មានព្រះបន្ទូលសូត្រសានូវព្រះគាថា នឹងព្រះសារី

Websites: WatKhemaraRatanaram.org or WatKhmers.org

បុត្តត្ថេរថា ៖

និក្ខមិត្វាន នគរា　　　　និវត្តិត្វា វិលោកិតេ
តទាបិ បថវី កម្បិ　　　　សិនេរុវនវដំសកាតិ ។

ហៃសារីបុត្តត្ថេរអើយ នាកាលអញតថាគត នៅជាព្រះវេស្សន្តរនោះ ស្តេចបង្វិលរាជរថចេញពីជេតុត្តរនគរនោះហើយ ទ្រង់រមិលមើលទៅកាន់ពិភពព្រះវរមាតាបិតាកាលឯណាមិញ ក៏អស្ចារ្យកើតមាននាគ្រានោះមហិមាប្រាកដ ។ រីមហាប្រឹថពីមានកម្រាស់នោះ ២ សែនអធិកនីទៅនូវ ៤ មុឺនយោជន៍ សឹងកក្រើកញាប់ញ័រ រីភ្នំព្រះសិនេរុរាជនោះ មានកំពស់ ៨ មុឺន ៤ ពាន់យោជន៍ក្តី ភ្នំហេមពាន្តក្តី ភ្នំសត្តបរិភណ្ឌក្តី សឹងដ៏មានកំពូលឱនលំទោន ទន់ល្ហាសទៅកាន់ជេតុត្តរនគរនោះហោង ។

សោ បន សយំ ឱលោកេត្វា មទ្ទីបិ ឱលោកាបេតុំ គាថមាហ ។ ឮដ៏កាលនោះ ព្រះមហាក្សត្រ ទ្រង់រមិលមើលអាត្មាព្រះអង្គឯងហើយ ទើបស្តេចទតមើលទៅព្រះនាងមទ្រី យល់ត្រមោចម្នាក់ឯង ឥតមានអ្នកឯណាមួយជាគ្នាឡើយកូវ ទើបស្តេចមានម្នាក់

Websites: WatKhemaraRatanaram.org or WatKhmers.org

ឯង ឥតមានអ្នកឯណាមួយជាគ្នាឡើយកូវ ទើបស្ដេចមានព្រះបន្ទូលនឹងព្រះនាងមទ្រីជាបាទគាថាដូច្នេះ ៖

ឥជ្ឈ មទ្ទិ និសាមេហិ   រម្មរូបំវ ទិស្សតិ
អាវាសោ សិវិសេដ្ឋស្ស   បេត្តិកំ ភវនំ មមន្តិ ។

ហៃនាងមទ្រីអើយ ចូរនាងពិតពិលរមិលមើលទៅឯពិភពលំនៅព្រះវរមាតាបិតានៃយើង នូវអ្នកស្រីពិរាស្ត្រផងទាំងឡាយ យល់ល្អប្រសើរក្រៃពេកហោង ។ ឮដ៏កាលនោះ ព្រះមហាក្សត្រកាលស្ដេចបររាជរថពីនោះទៅហើយ ស្ដេចមានបន្ទូលទៅនឹងអាមាត្យទាំង ៦ ម៉ឺនអម្បាលដែលកើត ថ្ងៃជាមួយនឹងព្រះអង្គនោះ ទើបស្ដេចមានព្រះបន្ទូលនឹងមហាជនផង នាថ្ងៃដែលហៃក្សនជូនដំណើរព្រះអង្គ ស្ដេចបររាជរថពីនោះបន្តិចកូវ ក៏ស្ដេចមានព្រះបន្ទូលនឹងនាងមទ្រីថាដូច្នេះ

ភទ្ទេ សចេ បច្ឆតោ យាចកា អាគច្ឆន្តិ ឧបធារេយ្យាសីតិ

ថាហៃនាងមទ្រីអើយ នាងជិះរាជរថបែរមុខទៅ ឯក្រោយមើលឲ្យដឹងក្រែងមានស្មូមតាមមកសូមយើងហោង ។

អថស្ស សត្តសតកមហាទានំ សម្បាបុណិតុំ អសក្កោន្តា

Websites: WatKhemaraRatanaram.org or WatKhmers.org

ចត្តារោ ព្រាហ្មណា ឯតរំ អាគន្ត្វា កុហឹ រាជាតិ បុច្ឆិត្វា អស្សេជំ យាចិស្សាមាតិ អនុពន្ធឹសុ ។

ឰដ៏កាលនោះ មានព្រាហ្មណ៍ ៤ នាក់ ពុំបានទទួលសត្តសតកមហាទាន អំពីព្រះមហាក្សត្រនៅឡើយ ។ ព្រាហ្មណ៍ទាំង ៤ នាក់នោះ ក៏ដើរចូលទៅក្នុងកំឡុងព្រះនគរនោះហើយ ដណ្ដឹងសួរអស់មហាជនផងទាំងឡាយថា ហៃអ្នកទាំងឡាយអើយ វីព្រះបាទស្រីវេស្សន្តរ ស្ដេចទៅកាន់ឋានឯណាបាត់ហើយ ។ ក្សិណនោះមហាជនផងស្ដាប់បានហើយឆ្លើយថា ហៃព្រាហ្មណ៍អើយ ព្រះបាទស្រីវេស្សន្តរជាម្ចាស់នៃយើងនេះ អ្នកឲ្យទានស្រេចហើយក្ដូវ ស្ដេចចេញទៅពីព្រះនគរនេះហើយ ឥឡូវនេះប្រស្ដែងមកដំណឹងរកនរណាវិញទៀតបាៈ ។ ព្រាហ្មណ៍ដណ្ដឹងសួរទៀតថា បើដូច្នោះ អ្នកមានបើយកអ្វីទៅជាមួយខ្លះ? អស់មហាជនផងស្ដាប់ហើយ ឆ្លើយថា ហៃព្រាហ្មណ៍អើយ! ស្ដេចមានតែរាជរថនោះឯង គ្រាន់តែដាក់ព្រះរាជទេពីនិងបុត្រាបុត្រីតែប៉ុណ្ណោះ ។ ក្សិណនោះ ព្រាហ្មណ៍ ទាំង ៤ នាក់គិតព្រមគ្នាថា ហៃគ្នាយើងអើយ មកយើងនឹងទៅតាមសុំយកសេះ

អាជានេយ្យទាំង ៩ ដែលទឹមអ្នកយកទៅនោះហោង ។

អថ មទ្ទី តេ អាគច្ឆន្តេ ទិស្វា យាចកា អាគច្ឆន្តិ ទេវាតិ អារោចេសិ ។ ឮដំកាលនោះ សម្តេចព្រះនាងមទ្រីរមិលមើលទៅយល់ព្រាហ្មណ៍ ៤ នាក់ដើរមកដូច្នោះក្តី ព្រះនាងទូលព្រះពោធិសត្វមហាបុរសវ័ត្នថា «បពិត្រអម្ចាស់អើយ ឥឡូវនេះមានស្មូមដើរមកតាមក្រោយយើង ។

អថ មហាសត្តោ រថំ ឋបេសិ ។ ក្សិណោនោះ ព្រះមហាសត្វ ព្រះអង្គបញ្ឈប់រាជរថដាក់រង់ចាំព្រាហ្មណ៍ លុះព្រាហ្មណ៍នោះ ដើរទៅដល់ព្រះពោធិសត្វហើយ ក៏ទូលសូមសេះអាជានេយ្យទាំង ៤ ស្តេចក៏ដោះសេះចេញពីរាជរថ ហើយឲ្យទៅជាទានព្រាហ្មណ៍ពុំមានស្តាយឡើយ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គបន្ទូលស្វូត្រសាន្ធូវព្រះគាថាដូច្នេះ ៖

តំ ព្រាហ្មណា អន្វគមុំ តេ តំ អស្សេ អយាចិសុំ

Websites: WatKhemaraRatanaram.org or WatKhmers.org

យាចិតោ បដិចាទេសិ ចតុន្នំ ចតុរោ ហយេតិ ។

ភិក្ខុអើយ កាលព្រាហ្មណ៍ទាំង ៤ នាក់ ទៅតាមសុំសេះអាជានេយ្យទាំង ៤ នោះក្ដី ព្រះអង្គដោះសេះអាជានេយ្យទាំង ៤ ពីរាជរថ ឲ្យទៅជាទាន ឫដ៏ក្សិណនោះពុំក្រដល់តិចឡើយ ។

អស្សេសុ បន ទិន្នេសុ រថធុរំ អាកាសេយេវ អដ្ឋាសិ ។ ហៃភិក្ខុអើយ កាលព្រះមហាក្សត្រឲ្យទានសេះអាជានេយ្យទាំង ៤ ក្នុងកាលឯណាមិញ វីត្បូងរាជរថនោះ ក៏ងើយចំពោះស្មោះទៅនាកណ្ដាលអាកាសហោង ។

អថ ព្រាហ្មណេសុ គតមត្តេសុយេវ ចត្តារោ ទេវបុត្តា រោហិតមិគវណ្ណោ ជាតន្ត្វា រថធុរំ សម្បដិច្ឆិត្វា អគមំសុ ។

ភិក្ខុអើយ ឫដ៏កាលនោះ ព្រះមហាក្សត្រឲ្យទានសេះអាជានេយ្យទាំង ៤ ទៅជាទានព្រាហ្មណ៍ទាំង ៤ នោះហើយ ខណៈនោះមានទេវបុត្រ ៤ អង្គ និម្មិតអាត្មា យកភៀសជារមាំងមាស ៤ មកទទួលរាជរថព្រះមហាសត្វហើយនាំព្រះអង្គទៅហោង ។

មហាសត្តោ តេសំ ទេវបុត្តាភាវំ ញត្វា ឥមំ គាថមាហ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះមហាសត្វទ្រង់ជ្រាប នូវភាពនៃម្រឹគអស់នោះជាទេវបុត្រ ហើយទើបព្រះអង្គមានព្រះបន្ទូលនឹងសម្តេចព្រះរាជមទ្រី ដោយនូវបាទព្រះគាថាដូច្នេះ ៖

ឥដ្ឋេ មទ្ទិ និសាមេហិ ចិត្តរូបំវ ទិស្សតិ
មិគា រោហិច្ចវណ្ណេន ទក្ខិណស្សា វហន្តិ មន្តិ ។

ហៃនាងមទ្រីអើយ ចូរនាងរមិលមើលទៅយល់រមាំងមាសទាំង ៤ នោះល្អដូចសេះអាជានេយ្យ គិតដំអ្នកឲ្យសិក្សាប្រពៃហើយមកនាំរាជរថយើងនេះទៅ ។

អថ ធំ ឯវំ គច្ឆន្តំ អបរោ ព្រាហ្មណោ អាគន្ត្វា រថំ យាចិ ។ ឮដំកាលនោះ មានព្រាហ្មមួយវិញទៀត មកសុំរាជរថអំពីព្រះមហាក្សត្រនោះសោត ព្រះអង្គក៏ដាក់ព្រះរាជបុត្រ និងព្រះរាជទេពីពីរាជរថនោះហើយក្ងរ ស្តេចក៏ឲ្យរាជរថទៅជាទានព្រាហ្មណ៍នោះហោង ។ កាលបើព្រះអង្គឲ្យទានរាជរថនោះហើយក្ងរ រីអស់ទេវបុត្រនោះវិញ ក៏និម្មិតកំបាំងអាត្មាភៀសចៀសបាត់ទៅហោង ។

រថស្ស បន ទិន្នភាវំ បកាសេន្តោ សត្ថា អាហ ។ រីព្រះ

Websites: WatKhemaraRatanaram.org or WatKhmers.org

សព្វេជ្ញ ស្តេចបានត្រាស់ប្រាជ្ញាសព្វេជ្ញូតាញាណ នាំនិទានអាស្រ័យព្រះរាជរថឲ្យប្រាកដ បទព្រះបាលីឯក្រោយ អំពីព្រះមហាក្សត្រឱ្យទានព្រាហ្មណ៍នោះក្ដី ព្រះបន្ទូលសូត្រសាន្ធវព្រះគាថាដូច្នេះ ៖

អថេត្ថ បញ្ចមោ អាគា    សោ តំ រថមយាចថ
តស្ស តំ បដិយាទាសិ    ន ចស្សុ បហតោ មនោ ។
តតោ វេស្សន្តរោ រាជា    ឱរោបេត្វា សកំ ជនំ
អស្សាសយិ អស្សរថំ    ព្រាហ្មណស្ស ធនេ សិនោតិ។

ហៃភិក្ខុអើយ កាលព្រះបាទស្រីវេស្សន្តរ បវរពោធិសត្វមហាបុរសរ័ត្ន ស្តេចចេញទៅពីស្រុកពិជ័យជេតុត្តរមហានគរនោះ ព្រាហ្មណ៍ ៤ នាក់ រត់ទៅតាមសុំសេះអាជានេយ្យ មានព្រាហ្មណ៍ម្នាក់ទៀតជាគំរប់ ៥ ទៅតាមសុំព្រះរាជរថ ព្រះអង្គក៏ព្រះរាជទានឲ្យព្រាហ្មណ៍នោះ ទុកជាការកម្រអម្បាលម៉ានក្ដី ក៏ព្រះពោធិសត្វនឹងមានព្រះរាជហឫទ័យ កក្រើកដោយនូវចិត្តកំណាញ់នោះ ឥតអង្គីមានឡើយ ។ ហេតុតែព្រះអង្គ នឹងបានត្រាស់ជាព្រះពុទ្ធនោះទៀងប្រាកដហោង ។

Websites: WatKhemaraRatanaram.org or WatKhmers.org

កាលព្រះបាទស្រីវេស្សន្តរ ដ៏ជាស្តេចធំ ទ្រង់តែងចំរើនអ្នកស្រុកស្រីពិរាស្រ្ត ស្តេចឲ្យទានរាជរថទឹមនីទៅនូវសេះអាជានេយ្យទាំង ៤ ទៅព្រាហ្មណ៍ស្មូមនោះក្ងរ ព្រះអង្គដាក់ព្រះរាជបុត្រ ព្រះរាជទេពីចុះពីរាជរថនោះហើយ ព្រះអង្គលួងលោមបណ្តើរទៅ ដោយនូវព្រះបាទាទទេហោង ។

អថ មហាសត្តោ មទ្ទឹ អវោច ។ អណ្តាប់នោះ ព្រះមហាសត្វ ស្តេចបន្ទូលនឹងសម្តេចព្រះរាជមទ្រីថាដូច្នេះ ៖

ត្វំ មទ្ទិ កណ្ហំ គណ្ហាហិ លហុកា ឯសា កនិដ្ឋកា
អហំ ជាលឹ គណ្ហិស្សាមិ គរុកោ ភាតិកោ ហិ សោតិ។

ហៃនាងមទ្រីអើយ ចូរនាងពមេក្រស្នា ដ៏ជាក្មេងស្រីតូចស្រាល ឯអញនឹងពថៅជាលីដ៏ជាបងច្បង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ នឹងបទព្រះបាលីឯក្រោយ ព្រះដ៏ជាគ្រូបានត្រាស់ហើយ ទ្រង់មានព្រះបន្ទូលសូត្រសានូវព្រះគាថាដូច្នេះ

រាជា កុមារមាទាយ រាជបុត្តី ច ទារិកំ

Websites: WatKhemaraRatanaram.org or WatKhmers.org

សម្មោទមានោ បក្កាមុំ អញ្ញមញ្ញំ ឋិយំ វទាតិ ។

ហៃភិក្ខុអើយ រីព្រះបាទស្រីវេស្សន្តរ ដ៏ជាក្សត្រប្រសើរនោះ ស្តេចពចៅជាលីដ៏ជាកូនច្បង រីសម្តេចព្រះរាជមទ្រីពនាងក្រស្នា ដ៏ជាកូនស្រីក្មេងតូចនោះ ។ រីក្សត្រទាំង ២ ព្រះអង្គ មានព្រះទ័យស្រណុក មិនជាទុក្ខឡើយ ។ ទ្រង់មានពាក្យពីរោះស្រដីទៅមក ដោយនូវដំណើរទៅតាមផ្លូវនោះហោង ។

ឆាឥកណ្ឌំ ។ រីនឹងស្រដីសរសើរ នូវដំណើរទានកណ្ឌនេះមិញ ដ៏ប្រដាប់នីទៅនូវព្រះគាថាទាំងឡាយ ២០៩ ព្រះគាថា និដ្ឋិតំ ក៏ចប់ជាសូរេច ដោយនូវប្រការអម្បាលណោះហោង ៕ល៚

(ចប់ទានកណ្ឌ ទី ៣ តែប៉ុណ្ណោះ)

---

Websites: WatKhemaraRatanaram.org or WatKhmers.org

វាយខំព្យូទ័រសាឡើងវិញ

ដោយ

**លោកគ្រូអាចារ្យ ឈឹម សំបូរ**

និង

ត្រួតពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ

ដោយ

លោកគ្រូ **ធម្មនាថ ផនប្រសិទ្ធី**

ដើម្បីផ្សព្វផ្សាយ ជូនជាធម្មទាន តាមវិបសាយ

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទានឈ្នះអស់ទានទាំងពួង

Websites: WatKhemaraRatanaram.org or WatKhmers.org